## ភាគទី ១២

# សង្គ្រាមកុរុក្សេត្រ

ព្រះក្រឹស្ណៈ នាំសារទៅកាន់រាជដំណាក់កុរុ មិនបានសម្រេចផលដូចបំណង, ហើយត្រឡប់មកវិញមិនយូរប៉ុន្មាន ទុរយោធន៍ក៏បញ្ជូនរាជសារបបួលច្បាំងទៅដល់បាណ្ឌពក្សត្រិយ៍ ក្នុងរាជសារបញ្ជូនច្បាំងនោះ សឹងពេញទៅដោយពាក្យប្រមាថមើលងាយជាយ៉ាងធ្ងន់បំផុត មានមនោសញ្ចេតនាប្រុងតែនឹងប្រើអាវុធ គឺធ្វើការមើលងាយជាងការប្រកាសសង្គ្រាម សេចក្ដីរាជសារនោះថា «ទ្រង់ស្បថទុកថា ទ្រង់នឹងធ្វើសង្គ្រាមដណ្ដើមយកជ័យនឹងយើង ឥឡូវនេះដល់ពេលវេលាហើយ ដែលទ្រង់ត្រូវប្រតិបត្តិតាមសម្បថដ៏ពិតប្រាកដនោះ, រាជអាណាចក្ររបស់ទ្រង់ត្រូវយើងរឹបអូសយក, នាងទ្រៅបទីទេវីរបស់ទ្រង់ក៏ត្រូវយើងធ្វើការផ្ចាញ់ផ្ចាល ឲ្យបាននូវសេចក្ដីអាម៉ាសមុខស្មើរតែដកដង្ហើមមិនរួច ព្រះអង្គទ្រង់ព្រមទាំងបងប្អូនត្រូវយើងសង្កត់កនិរទេសឲ្យទៅនៅព្រៃដូចពានរ ភីម យក្សធំមាត់រឹងអួតខ្លោលតែមាត់នោះ គេចមុខទៅពួនឯណាបាត់ ភ្លេចហើយឬសំដីដែលអួតគឃរ ថានឹងផឹកឈាមទុហាសាសនៈ ? ទុហាសាសនៈ រង់ចាំមើលតែមាត់ឈ្លើង ដែលនឹងមកជញ្ជក់ឈាម, អរជុន អ្នកអួតខ្លាំងពូកែណាស់ តើគេទៅពួននៅឯណាបាត់ទៅ ? ឲ្យគេចេញមកអំពីទី

ពួនមុខចុះ ហើយសិល្បសរដូចយ៉ាងក្មេងវត្តទើបហាត់រៀន ឲ្យយើងមើលផង តើនឹងជាអ្វីទៅ » សេចក្ដីក្នុងសារនេះនៅវែងពិស្ដារផ្សេង ៗ ជាច្រើនទៀត ។

ពួកបាណ្ឌពទទួលពាក្យ បបួលច្បាំងនេះទុកហើយ បានបញ្ជូនពាក្យប្រកាសសង្គ្រាមតបទៅដល់ពួកកុរុវិញ ប៉ុន្តែប្រើសំដីសុភាពរៀបរយតាមទំនៀមរាជការ ។

លុះដល់ព្រឹកឡើង កងទ័ពទាំងពីរខាង គឺកងទ័ពកោរព និងបាណ្ឌព ក៏លើកមកតាំងនៅទីវាលធំ ដ៏មិនឆ្ងាយអំពីក្រុងហាស្តិនបុរប៉ុន្មាន តាំងពីពេលនោះមកមានប្រាកដក្នុងពង្សាវតារថា «សង្គ្រាមកុរុក្សេត្រ» ។

ភីស្មៈ ត្រូវរើសជាស្ដេចសឹកកំពូលទ័ពខាងកងទ័ពកុរុ, ទោណាចារ្យជាអ្នកបញ្ជាការទ័ពស្លាបស្ដាំ គឺជាមេទ័ពខាងស្ដាំ មានសកុនិជាជំនួយ (ភូឈួយ) និងកងទាហានគន្ធារិ ជិះសេះកាន់ធ្នូ, ទុហាសាសនៈជាអ្នកបញ្ជាការទ័ពស្លាបឆ្វេង គឺជាមេទ័ពខាងឆ្វេង ព្រះធ្មតរាស្ត្រជាអ្នកបញ្ជាកងទ័ពក្រោយ មានសញ្ជ័យជានាយសារថីរបស់ព្រះអង្គនៅជាមួយផង ចាំក្រាបទូលរាយការណ៍អំពីសេចក្ដីប្រតិបត្តិការនៅក្នុងទីចម្បាំងឲ្យទ្រង់ជ្រាប ។

កងទ័ពបាណ្ឌពមាន ធ្រស្តទ្យុម័ន ជាឱរសរបស់ព្រះបាទទ្រុបទបងប្អូនទ្រៅបទីជាមេទ័ពស្រួច អ្នកនាំទ័ពខាងបាណ្ឌព ។ ក្នុងកងទ័ព



បាណ្ឌពមានក្សត្រិយ៍កំលោះ ៗ ជាច្រើនអង្គ, បណ្ដាក្សត្រិយ៍កំលោះទាំងនោះ អភិមន្យុជាបុត្ររបស់អរជុន កើតពីនាងសុភទ្រាជាកនិដ្ឋភគិនីនៃព្រះក្រឹស្ណៈ ក្មេងក្លាងជាងគេទាំងអស់ ។ កងទ័ពរបស់ទុរយោធន៍ មានកម្លាំងរេហ៍ពលរឹងប៉ឹងជាងកងទ័ពរបស់យុធិស្ឋិរ ។

អ្នកនាំទ័ពទាំងពីរខាង មានសេចក្ដីរីករាយសប្បាយចិត្តជាយ៉ាងក្រៃលែងបានចាត់ក្បួនទ័ពដោយរួសរាន់ ។ ទង់ពណ៌ឥន្ទធនូរបស់កងទ័ពទាំងពីរខាង បោកបក់រវិចទៅតាមខ្យល់ ត្រែខ្លីក៏ផ្លុំសូរស័ព្ទសាំនរងំ ទាំងយុទ្ធមណ្ឌល ។ ស្គរជ័យក៏ទូងឮសូរទូង ៗ បណ្ដើរអន្លូងជាចង្វាក់សម្រាប់ប្រាប់ហេតុ ។ ដំរីសឹកសោតក៏ស្រែក កក ៗ ឮសូរសន្ធឹកសូរស័ព្ទស្ទើរផ្កាប់ប្រឹថពី ។ រថសឹកទឹមសេះពាជីគ្រឹក ៗ ឮសូរសន្ធឹកដូចផ្គរលាន់ ។ គ្រឿងអាវុធយុទ្ធភ័ណ្ឌបានប្រុងប្រៀបត្រៀមទុកស្រេចគ្រប់មុខគ្រប់យ៉ាង ។ សេនាទាហានទាំងពីរខាងសម្រិតសម្រាំងផ្សេងត្រចៀកចាំស្ដាប់ស័ព្ទបញ្ជានាយចៅហ្វាយរបស់ខ្លួនដែលស្រែកឲ្យប្រុងចូលវាយសឹក ។

ក្នុងខណៈដែលកងទ័ពទាំងពីរខាងកំពុងឈប់ឈរទ្រឹងសម្លឹងសម្លក់មុខគ្នានិងគ្នាទៅវិញទៅមកនោះ ឃើញមានហេតុចម្លែកអស្ចារ្យមួយយ៉ាងកើតឡើងប្រាកដដល់ភ្នែកមនុស្សទាំងឡាយ គឺយុធិស្ឋិរចុះអំពីរថសឹក ហើយដោះគ្រឿងសឹកចេញអំពីព្រះអង្គ យាងតម្រង់ទៅរកអ្នកបញ្ជាការកងទ័ពខាងកុរុ ដែលឈរត្រៀបត្រាពីខាង

មុខ ប៉ុន្តែទ្រង់ឥតកាន់អាវុធអ្វីនៅព្រះហស្តសោះ នេះជាបុព្វនិមិត្តសម្រាប់សំគាល់ឲ្យឃើញថា ទ្រង់មកដើម្បីសន្តិភាពស្ងប់សឹក ព្រោះតាមកតិកាអ្នកស្រុកឥណ្ឌៀថា អ្នកចម្បាំងណានឹងទៅប៉ះពាល់ដល់រូបកាយបច្ចាមិត្រដែលឥតអាវុធក្នុងដៃនោះមិនបានជាដាច់ខាត ។ ឯពួកសេនាទាហានខាងពួកយុធិស្ធិរ សឹងនឹកឆ្ងល់តែរាល់គ្នា ។ ខាងពួកកុរុនាំគ្នាសប្បាយរីករាយណាស់ដោយសំគាល់ថា យុធិស្ធិរស្ងប់ស្វែងក្រែងខ្លាចបារមី បានជាចុះពីរថចូលមកសុំធ្វើសញ្ញាសន្តិភាពឈប់ច្បាំងត្រឹមប៉ុណ្ណឹង ហើយនាំគ្នាបង្អង់មួយស្របក់ គ្មានអ្នកណាហ៊ានធ្វើអ្វីសោះ ប៉ុន្តែឯភ្នែកមនុស្សគ្រប់រូបចេះតែប្រឹងសម្លឹងត្រង់ចំពោះទៅយុធិស្ធិរ នៅពេលដែលកំពុងស្តេចយាងចូលទៅរកនាយទាហានធំខាងកុរុ មើលទៅព្រះភក្ត្រនៃយុធិស្ធិរ បញ្ជាក់ឲ្យយល់ថា ទ្រង់មិនសប្បាយព្រះទ័យសោះឡើយ ។

ក្សិណនោះ យុធិស្ធិរយាងសំដៅទៅរកភីស្ម: ដែលកំពុងឈរនៅក្នុងចំណោមទាហានជួរមុខ ទ្រង់យាងសន្សឹម ៗ ចូលទៅស្ទាបព្រះបាទភីស្ម: ហើយសូមខមាទោសដើម្បីនឹងធ្វើសង្គ្រាមប្រឡូងប្រជែងយកជ័យជម្នះ ព្រោះតាមធម្មតា ក្សត្រិយ៍អ្នកធ្ងន់ក្នុងអារ្យចិត្ត កាលបើបានជ្រាបថា ព្រះអង្គនឹងកាន់អាវុធចូលធ្វើសង្គ្រាមជាមួយព្រះញាតិវង្សអ្នកធំដ៏ជាមេបារបស់ត្រកូល បើមិនទាន់បានសូមខមាទោសជាមុនទេ នឹងធ្វើចម្បាំងមិនបានឡើយ សូម្បីជេដ្ឋបុគ្គលនោះ



កាន់អាវុធចូលមកប៉ុនប៉ងនឹងប្រហារខ្លួនក្តី ស្រេចការសូមខមាទោសនេះហើយ ទ្រង់យាងចូលទៅរកទោណាចារ្យសូមខមាទោស នឹងអាចារ្យថា «ទ្រង់ត្រូវតែហ្វតក្រប៊ី តយុទ្ធនឹងពួកកុរុ នៅគ្រានេះហើយ ទ្រង់គ្មានមនោសញ្ចេតនា ប្រាថ្នាតស៊ូនឹងអាចារ្យ ឬនឹងបក្ខពួករបស់អាចារ្យអ្នកស័ក្តិសិទ្ធិ ដែលទ្រង់បានសិក្សាសិល្បសរ អំពីលោកនោះសោះឡើយ » ។ អ្នកចម្បាំងជើងចាស់ទាំងពីរ ក៏អនុមតិព្រមលើកទោសយុធិស្ធិរ តាមពាក្យសុំស្រេចហើយ បាណ្ឌពរាជាក៏លាថយចូលទៅក្នុងកងទ័ពរបស់ព្រះអង្គវិញ ។

ក្សិណនោះកងទ័ពទាំងពីរខាងបានស្រែកប្រកាសតាមទំនៀមថា «ចូលទីសង្គ្រាមធំ ឥតមានសមគំនិតនឹងអ្នកណាទេ» ។

អរជុនឲ្យក្រឹស្ណ:ជារាជសម្ព័ន្ធមិត្ររបស់គេ ទទួលនាទីបររថសឹក នាទីឯទៀតមិនស្រួលដូចនាទីនេះឡើយ ព្រោះក្រឹស្ណ:បានប្តេជ្ញានឹងទុរយោធន៍ ថាទ្រង់នឹងមិនកាន់អាវុធដើម្បីចូលជួយខាងពួកបាណ្ឌព ។ កាលអរជុនឡើងលើរថសឹកដ៏ខ្ពស់ហើយ ក្រឡេកទៅក្រួតមើលជួរទាហានសឹកខាងមុខ សង្កេតឃើញពួកទាហានទាំងអម្បាលនោះ សុទ្ធតែជាព្រះញាតិរបស់ខ្លួន ទាំងចាស់ទាំងក្មេង ក៏ទ្រង់ស្លុតព្រះហឫទ័យ ទើបទ្រង់ត្រាស់ប្រាប់ព្រះក្រឹស្ណ:ថា «ចិត្តខ្ញុំរសេះរសោះរួញរាក្នុងការធ្វើសង្គ្រាមកាប់សម្លាប់គ្នា ឈាមប្រាលទាំងប្រឹថពីក្នុងទីចំពោះមុខនេះណាស់, ខ្ញុំមិនចង់ស្វែងរកជ័យជម្នះ

ដោយការបៀតបៀនគ្នាយ៉ាងនេះសោះឡើយ, ខ្ញុំមិនចង់ខ្វល់ខ្វាយរកអំណាច, ខ្ញុំមិនប្រាថ្នាសេចក្ដីចម្រើនក្នុងលោកនេះទេ, យើងលោភចង់បានផលប្រយោជន៍ឲ្យអ្នកណា អ្នកនោះក៏មកចូលក្បួនទ័ពច្បាំងនឹងយើងដែរ, ប្រយោជន៍អ្វីដែលយើងនឹងត្រូវបានក្នុងលោកនេះ, សេចក្ដីសុខក្នុងលោកនេះនឹងកើតមកពីណា បើយើងចេះតែសម្លាប់បងប្អូនឯង ឲ្យស្លាប់អស់រលីងទៅហើយ»។

ក្រឹស្ណៈទ្រង់ត្រាស់ដាស់តឿនថា «អ្នកចម្បាំងដែលខំតស៊ូច្បាំងគ្នានោះ ក៏គេមិនមែនប៉ុនប៉ងស្វែងរកសេចក្ដីល្អ ឬកិត្តិយសទេគេមិនមែនច្បាំងសម្រាប់លោក ឬសម្រាប់ធម៌ទេ, គេមិនមែនច្បាំងសម្រាប់អ្នកជិតស្និទ្ធ ឬអ្នកដទៃឆ្ងាយទេ គេច្បាំង ឬមិនច្បាំងគ្រាន់តែដើម្បីប្រតិបត្តការតាមនាទីប៉ុណ្ណោះ ដោយមិនត្រូវនឹកសង្ឃឹមដល់ផលណាមួយ ក្នុងទីបំផុតយកមកធ្វើជាអារម្មណ៍ក្នុងចិត្តឡើយ, ទ្រង់ជាតិជាក្សត្រិយ៍ (ជាតិអ្នកចម្បាំង) ហើយការនេះជានាទីរបស់ទ្រង់ ត្រូវតែទ្រង់ច្បាំងជំនួសព្រះរាជារបស់ទ្រង់យ៉ាងពេញសតិកម្លាំង នឹងបានសម្រេចផលក្នុងទីបំផុតដូចម្ដេចក៏តាមការទៅចុះ ទោះបីជាការសម្រាប់ខ្លួនក្ដី សម្រាប់អ្នកដទៃក្ដី មិនត្រូវលើកយកមកគិតនឹកជាអារម្មណ៍ ប៉ុន្តែសូមកុំប្រកាន់យកសំដីរបស់ខ្ញុំ ថាជាគ្រឿងសន្ទាប់ឲ្យខ្លាចហើយធ្វើការទៅទាំងប្រថុយដោយសាតែគេចវេះទៅណាមិនរួចនោះឡើយ បើនិយាយអំពីកិត្តិយសវិញ កិត្តិយសរបស់អ្នកចម្បាំង



នៅត្រង់ការច្បាំងនោះឯង, បើនិយាយអំពីមរណភាពវិញ គ្មានមរណភាពឯណា នឹងឲ្យល្បីល្បាញកេរ្តិ៍ឈ្មោះជាងមរណភាពក្នុងសង្គ្រាមឡើយ ខ្ញុំសូមប្រកាសិតទុកក្នុងទីនេះថា មិត្រសម្លាញ់និងគណញាតិរបស់ទ្រង់, គេកាន់គ្រឿងសស្ត្រាវុធចូលតស៊ូនឹងទ្រង់ហើយ ប៉ុន្តែនឹងមករំលោភលើទ្រង់ម្នាក់ឯងមិនបានទេ, ឯទ្រង់សោតនឹងកែខៃដោះដៃចេញពីរឿងនេះក៏មិនរួចដែរ, ចូរទ្រង់រឭកនឹកដល់ព្រះធម៌ពាក្យប្រដៅដ៏ស័ក្ដិសិទ្ធិរបស់អ្នកចម្បាំង ហើយធ្វើដំណើរការតាមនោះទៅចុះ ធ្វើជាមនុស្សចិត្តទន់ហួសពេកក្នុងទីចម្បាំងយ៉ាងនេះនឹងហៅថាពេញជាកូនប្រុសបានដែរឬទេ ? ប៉ុន្តែណ្ហើយចុះ ខ្ញុំឈប់និយាយសង្កត់សង្កិនទ្រង់ត្រឹមនេះហើយ, ឯសេចក្ដីអធ្យោគអធ្យាស្រ័យយល់មុខយល់មាត់នេះឯង រមែងធ្វើឲ្យខូចការទាំងអស់»។

អរជុនសម្រឹងសោតស្ដាប់ក្រឹស្ណៈ រៀបរាប់រំឭកសព្វ ៗ ទៅ ក៏កើតមានះមានចិត្តនឹងច្បាំងតទៅ។

គ្រានោះ ឮសូរសម្លេងស្ដេចសឹកម្នាក់ស្រែក ដោយសូរស័ព្ទធ្ងន់ក្រអួនថា « ច្បាំង ៗ ! » ក្នុងមួយរំពេចនោះ ក៏កើតកោលាហលដូចជាខ្យល់កំបុតត្បូងបោកបក់មកអំពីទិសទាំង ៨ ត្រែចម្បាំងក៏បន្លឺសូរស័ព្ទគឹកកងរំពងដងព្រៃ, ស្គរជ័យបញ្ចេញសម្លេងញាប់ទន្ទើនបាក់ដូចជាក្រើនទាហានឲ្យចូលប្រយុទ្ធគ្នា សម្លេងស័ង្ខប្រឆាំងនឹងសម្លេងស្គរធំឮសូររ៉ូ ៗ ទុំ ៗ រងំ ។ ពួកកោរពលើកចូលវាយលុក ដោយពល

សេះ, ពលថ្មើរជើង, ពលរថ និងពលដំរីសឹក ឮសូរស័ព្ទគគ្រឹកចូលមកស្ទើរកក្រើករបើកផែនពសុធា ។ ពួកបាណ្ឌពទទួលទប់ទល់ដោយរេហ៍ពលសកលយោធាប្រៀបជាថៃវជិតមីរដេដាសមាំដូចផែនសិលា, ទាហានតែម្នាក់ក៏មិនបានថយចាកចោលទីកន្លែងរបស់ខ្លួនសូម្បីតែមួយជំហានឡើយ, រំយោលស្លាបសត្វដែលដោតប្រដាប់នៅមួកមិនខ្ទេចខេចខុសប្រក្រតី សូម្បីតែមួយសរសៃក៏គ្មាន ។ ពួកបាណ្ឌពរុកចូលពព្រីបបីដូចខ្យល់កំបុតត្បូង ធ្វើឲ្យថៃវទាហានកុរុធន់ទ្រាំនៅមិនបាន ត្រូវថយចេញពីទីកន្លែងខ្លួន ។ ទ័ពទាំងពីរពួកសង្កុញសង្រ្កុករុករោមចោមតយុទ្ធគ្នាជាយូរ ឥតគិតស្តាយជីវិត ផង់ធូលីហើរហុយទ្រលោមគ្រឡប់អ័ព្ទផ្សែងទូទាំងសមរភូមិ ។

ក្សិណនោះ បណ្តាលឲ្យឃើញអាភេទហេតុអាក្រក់កើតមានមកពីគ្រប់ទិសទី មានភ្លៀងលោហិតធ្លាក់ចុះមកអំពីអាកាសក្រហមច្រាលដូចទឹកល័ខ, ផ្គៃព្រៃស្រែកលូឮសូរទ្រហឹងទាំងកណ្តាលថ្ងៃត្រង់, ខ្លែង និងត្មាតហិចហើរឆ្វៀលឆ្វាត់លើនភាកាស, ផ្ទៃពសុធាដែលក្រាស់ក្រៃលែង ក៏កម្រើករំពើកញាប់ញ័រខុសពីប្រក្រតី, បន្ទាប់មកទៀតឃើញមេឃមីរទូទឹម អស់អាកាសអន្ធិកា ងងឹតសូន្យសុងឃើញតែផ្លេកបន្ទោរផ្លេក ៗ ភ្លាម ៗ សូរផ្គរគ្រហឹមគ្រឹកគ្រាក់គំរាមលើនភាល័យ ហាក់នឹងធ្លាក់មកលើក្បាល អាភេទទាំងនេះមុខគួរឲ្យស្បើម ឲ្យស្ញែងជាយ៉ាងពន្លឹក ។ ប៉ុន្តែចិត្តចម្បាំងគ្រប់ប្រាណមិនបាន



រួញរាស្លុតរន្ធត់នឹងហេតុភេទដ៏អាក្រក់ទាំងនោះឡើយ នៅតែលេងសំដីឡកឡឺយឲ្យគ្នាទៅវិញទៅមក ឥតរួញរាថយក្រោយដល់បន្តិចសោះ ចេះតែរុករានទន្ទ្រានចូលប្រឡូកកាប់ចាក់ គ្មានស្រាកស្រាន្តគិតតែខំប្រឹងយកជ័យជម្នះឲ្យបានរៀងខ្លួន ឬលះបង់ជីវិតជាបំណាច់ផែនដីប៉ុណ្ណោះ ។ ក្របី និងក្របីប៉ះគ្នាឮសូរឆាត់ ៗ ឆាប់ ៗ ខ្លះឮតែញ៉ាំង ៗ ជួនកាលត្រូវខ្លាំង ក៏ខ្ទាត់ខ្ទេចខ្ទីទៅតែសព្វខ្លួន ។ កូនសររត់វ៉ឺ ៗ ប្រសាចលើអាកាស កលដូចជាគ្រាប់ភ្លៀងបង្អុរចុះមក ទាំងស្នូលំពែងសោត គឺពួយទៅមកច្រវាត់ច្រវែង ។ លុះដល់អាកាសភ្លឺព្រាងស្វាងឡើងហើយ ការច្បាំងក៏ចេះតែបណ្តើរក្សាច់ញឹកឡើង ៗ ដោយភ្លើងទោសៈ ។ ភីស្មៈអ្នកចម្បាំងជើងចាស់ ក៏ចេញទន្ទេងមកសម្តែងឫទ្ធិ ។ ទុរយោធន៍បររេហ៍ពលចូលមកទល់នឹងកងពលភីម ។ ទុហាសាសនៈលើកចូលប្រយុទ្ធគ្នានឹងនកុល ។ យុធិស្ឋិរលើកចូលវាយសល្យរាជានៃប្រទេសម័ទ្រៈ ។ ធ្រស្តទ្យុម័នចូលវាយជាមួយទោណ ។ ព្រះបាទទ្រុបទចូលតស៊ូនឹងជ័យទ្រថរាជានៃប្រទេសសិន្ធូ ។ តស៊ូប្រយុទ្ធគ្នាជាគូ ៗ ពេញទាំងទីសមរភូមិ ប៉ុន្តែនៅវេលានោះនៅពុំទាន់ឃើញផលថាខាងណាមានប្រៀបជាងខាងណាឡើយ ។

កងទ័ពទាំងពីរខាងបានតយុទ្ធគ្នាដោយមានះដ៏ខ្លាំងក្លាពេញមួយថ្ងៃទាល់ល្ងាច លុះធ្លាក់ដល់ពេលព្រលប់ទៀបយប់សន្ធយាអភិមន្យុយល់ឃើញថា ពួកកោរពមានប្រៀបជាងក្នុងជើងចម្បាំង ក៏

ស្មុះរហោចចូលទៅវាយភីស្មៈ ប្រហារទង់ជ័យនាំពល ដែលដោតលើរថភីស្មៈដោយក្របីដ៏មុតថ្លាដាច់ធ្លាក់ស្រយាលទៅលើផែនធរណី ។ តាំងពីកាលណា ៗ មក វីរបុរសភីស្មៈ អាយុជាង ៨០-៩០ ឆ្នាំមកហើយ ពុំដែលឃើញមានអ្នកចម្បាំងកំលោះណា ធ្វើការក្លាហានក្នុងសង្គ្រាមដល់ម្លេះសោះឡើយ។ ភីស្មៈលើកចូលលុកវាយទ័ពបាណ្ឌពជាគំរប់ពីរដងដោយមនោមនះដ៏រឹងឫទ្ធិ កាប់សម្លាប់កងទាហានបាណ្ឌពធ្លាក់ឈាមប្រាលមានរបួសនឹងស្លាប់ជាច្រើន ។ អរជុនឃើញពួកបាណ្ឌពទន់ដៃជាងពួកគេ ក៏បររថសឹកខ្ទាញ់ចូលទៅជួយទប់កម្លាំងពួកបាណ្ឌពបាន ។ បន្ទាប់អំពីនោះ អរជុនបររថសឹកសម្រុកចូលជ្រែកចំកណ្ដាលកងទ័ពកុរុដែលក្រាស់មីរដេរដាស កាប់សម្លាប់ស្លាប់បង់ឥតបីគណនាគ្រារាប់បាន ។ វេលានោះព្រះអាទិត្យគោចរទន់ទាបបិទបាំងភ្នំព្រះសុមេរុបាត់អស់រស្មី រាត្រីសម័យក៏ឈានចូលមកដល់ ។ ត្រែសញ្ញាឈប់ច្បាំងក៏បន្លឺសូរស័ព្ទតែត ៗ ឡើង ។ ការច្បាំងក្នុងថ្ងៃជាដំបូងនេះ ចប់ចុះត្រឹមប៉ុណ្ណេះ ។ លទ្ធផលនៃការសង្គ្រាមមិនទាន់ដាច់ស្រេចទៅខាងណា ។ ឯពួកពលសេនាទាហានសឹកទាំងពីរប្រទេស ក៏នាំគ្នាចូលសម្រាកកាយក្នុងបន្ទាយ ។

ពេញមួយរាត្រីនោះ យុធិស្ឋិរ ទ្រង់ខ្វល់ព្រះហឫទ័យគ្មានបានសម្រាកសម្រាន្តព្រះកាយព្រះទ័យសោះ ព្រោះជោគជ័យនៃការសង្គ្រាមបានកើតប្រាកដដល់ព្រះនេត្ររបស់ទ្រង់ហើយថា ឃើញធ្វើ



ការចេះតែទាស់ ៗ ទើសទាក់ មិនសូវបានស្រួលសោះ យប់នោះទ្រង់រំពឹងសព្វ ៗ ទៅ ក៏កើតសង្វេគក្នុងហឫទ័យ ទើបស្ដេចទៅរកក្រឹស្ណៈ អភិប្រាយហេតុផលតាមដែលគិតឃើញក្នុងព្រះទ័យឲ្យក្រឹស្ណៈស្ដាប់ ។ ក្រឹស្ណៈក៏ដាស់តឿនទ្រង់កុំឲ្យញញើត ឬភ្លឹកក្នុងរឿងសឹកសង្គ្រាមនេះឡើយ ។

លុះចប់ការសន្ទនាហើយ អរុណក៏រឿងរះត្រចះចែងអំពីទិសបូពា កាលបានវេលាឧសាយោគតាលធ្វជ គឺទង់ជ័យនាំទ័ព មានរូបភាពដើមត្នោតរបស់ភីស្មៈ ក៏តាំងលេចឡើងជាថ្មីយ៉ាងចិញ្ចែងលេងកន្ទុយរវិចលើស្នាមយុទ្ធ កងទ័ពទាំងពីរខាងក៏យាត្រាមកកាន់យុទ្ធមណ្ឌលចាប់ផ្ដើមការតតាំងច្បាំងគ្នាជាថ្មី ។ ឱរសព្រះបាទទ្រុបទចូលតយុទ្ធនឹងទោណ។ ភីមសម្ដែងសេចក្ដីក្លាហានចូលដេញប្រហារហ្វូងដំរីសឹកដែលពួកកោរពលែងមកជាន់ឈ្លើពលរបស់គេ ឲ្យបែកខ្ចាត់ខ្ចាយទៅទាំងហ្វូង ។ ទុរយោធន៍ទតឃើញពលរបស់ទ្រង់ កងខ្លះរត់ព្រាត់ប្រាសព្រាយទៅ ក៏ត្រាស់ពាក្យសឹកស្បែតចាក់ដោតឲ្យភីស្មៈថា «ភីស្មៈ ទ្រង់សំគាល់ព្រះអង្គទ្រង់ថាជាអ្នកនាំទ័ពកុរុនេះឬ ? ទ្រង់សំគាល់ថា ទោណជាកម្លាំងរបស់ទ្រង់ឬ ? ម្ដេចក៏ទ្រង់បង្អែបង្អង់រារង់ ប្រហែលជាទ្រង់មានព្រះទ័យមេត្តាប្រណីពួកបាណ្ឌពឬអី ? បើដូច្នេះ សុំឲ្យកណ៌ទទួលតំណែងជាមេទ័ពរបស់យើងវិញចុះ»។

ភីស្មៈឮពាក្យគោរសសូសដូច្នោះ ក៏បណ្ដាលទោសៈឡើងព្រះ

ភគ្គក្រញូវ ។ ព្រះទ័យទុរយោធន៍កំពុងពេញពាលមានសេចក្ដីរួតរះរហ័សចង់បានជ័យជម្នះ ឲ្យដាច់ស្រេចទាន់ចិត្តតែម្ដងក្នុងមួយថ្ងៃ លុះបានឃើញការមិនសម្រេចដូចព្រះទ័យ ក៏ដាលវ៉ាលកោសរួសទម្លាក់ទោសឲ្យភីស្មៈតែមួយអង្គឯង ប៉ុន្តែភីស្មៈជាមនុស្សមានចិត្តមានថ្វីដៃមកយូរណាស់ហើយ មិនមែនជាមកនៅទ្រាំឲ្យគេនិយាយសិកសៀតល្មេងទទេ ៗ យ៉ាងនេះឡើយ ទើបឆ្លើយតបដោយព្រះសូរសៀងញ័រ ៗ ដ៏ពេញទៅដោយទោសៈថា «ភីស្មៈ ឬទោណ ឬកណ៌ក្ដី មិនអាចនឹងលុបលាងមន្ទិលនៃអយុត្តិធម៌ ដែលធ្វើរំលោភមកលើច្បាប់ដោយឥតខ្មាសបាបដូច្នេះទេ ទ្រង់អាចនឹងឈ្នះហេតុដែលត្រឹមត្រូវតាមធម៌ដោយសេចក្ដីឈ្លាសវៃ លាយទៅដោយកលកោងរបស់ទ្រង់ឬ ? ខ្ញុំតស៊ូសឹកសត្រូវរបស់ទ្រង់យ៉ាងអ្នកចម្បាំងប្រកបដោយសត្យតាមសតិកម្លាំងនៃខ្លួនដែលនឹងអាចធ្វើបាន កុំបាច់ទ្រង់មកនិយាយចាក់ដោតដូច្នេះឡើយ, ត្រាស់យ៉ាងនេះហើយ ក៏តម្រង់ស្លុងចូលទៅច្បាំងវាយស្កាំ វាត់ឆ្វេងត្រឡប់ត្រឡិន បែកខ្ចាត់ខ្ចាយ ព្រោងព្រាតទៅខាងមុខ រថសឹកបាក់ខ្ទេចខ្ទី ហ្វូងដំរីសឹកក៏ភ្លូកភ្លឹកបោលព្រាត់ព្រាយ សេះសឹកជាយខ្ចាត់ខ្ចាយពុំហ៊ានទប់ទល់ រេហ៍ពលស្លាប់ត្រៀបត្រាប្រគងប្រគរលើគ្នា, អ្នកដែលរស់នៅក៏ជ្រួលច្របល់រត់ប្រពាក់ប្រពូនទៅប្រមូលផ្ដុំគ្នាពីជ្រុងខាងនេះ ទៅជ្រុងខាងនោះ ពីជ្រុងខាងនោះមកជ្រុងខាងនេះ ទប់ទល់កម្លាំងភីស្មៈស្ទើរពុំបាន



សូម្បីតែចិត្តអរជុនជាអ្នកធ្លាប់ក្លាហាន ក៏តោងរួញរាញញើតភីស្មៈមួយស្របក់ដែរ ប៉ុន្តែកើតចិត្តមានះឡើងដោយសារពាក្យក្រើនរំឭករបស់ក្រឹស្ណៈ ទើបអរជុនដេញពលសេះឲ្យចូលពាំងពាររាំងរាសឹកដែលរុកចូលមកនោះហើយវាយកាត់ថៃវទាហានសឹកដាច់ជាពីរភាគដេញតាមប្រហារបែកខ្ញែករត់ប្រាសទៅឆ្វេងទៅស្ដាំអស់ទៅ ។

ធ្លាក់ដល់វេលារសៀល បានឃើញការប្រយុទ្ធគ្នារវាងក្សត្រិយ៍កំលោះអ្នកចម្បាំងឯកពីរអង្គ គឺអភិមន្យុ បុត្រអរជុនម្ខាង និងលក្សណម័ន បុត្រទុរយោធន៍ម្ខាង ប៉ុន្តែដល់ចុងដៃឃើញលក្សណម័នទន់ជាងក្នុងក្បួនពិជ័យសង្គ្រាម ស្ទើរតែនឹងបរាជ័យ តែបានព្រះរាជបិតាចូលទៅជួយរួចមក ហើយពួកកុរុក៏ព្រួតគ្នាចោមរោមអភិមន្យុជិតជុំវិញ អភិមន្យុបានទទួលតស៊ូរាជសត្រូវគ្នាច្រើនតែម្នាក់ឯងមួយស្របក់ ខាងពួកទាហានបាណ្ឌពឃើញអភិមន្យុធ្លាក់ខ្លួនទៅនៅក្នុងចំណោមសឹក ក៏ស្រែកហៅអរជុន, អរជុនរលះរលាំងទៅជួយបុត្រទាន់ការ គ្រាន់តែឃើញរថសឹកអរជុនបរតម្រង់ចូលទៅ ពួកទាហានកុរុស្រែកថា «អរជុន ! អរជុន !» ហើយក៏នាំគ្នារត់ព្រាតទៅ ជួនជាដល់វេលាអស្តង្គតមានអាណត្តិសញ្ញាសម្រាកច្បាំងតាមទំនៀម ។

យុទ្ធវារៈថ្ងៃមួយទៀត លុះដល់ព្រឹកព្រាងស្វាងព្រះសុរិយា ពន្លឺអរុណឆ្លុះទៅចាប់នឹងផ្ទៃមេឃខាងទិសបូព៌ា ត្រូវគ្នានឹងផ្ទៃស្នាមយុទ្ធដែលក្រាលទៅដោយលោហិត ក៏រឹតតែធ្វើទីសមរភូមិនោះ ឲ្យក្រហម

ខ្លាំងណាស់ឡើង ។ លុះបានវេលាហើយ អ្នកចម្បាំងទាំងពីរប្រទេស ចាប់រៀបចំក្បួនទ័ព ហើយលើកព្រុហាយាត្រាចូលកាន់ទីសមរភូមិ ។ គ្រានោះ ខាងពួកបាណ្ឌព អ្នកវាយលុកចូលវិញ ចាត់ក្បួនទ័ពជារូបព្រះច័ន្ទ លើកពុះពារសម្រុកចូលទៅវាយទ័ពកុរុដោយចិត្តខ្លាំង កាប់ចាក់ស្លាប់រពាយ ឈាមហូរដក់ដូចទឹក សេះសឹកដួលដាច់ខ្យល់ងាប់រពឹង ដោយខំបោលអស់ដើង និងត្រូវអាវុធ ឮតែសម្លេងថ្ងូរនឹងស្នូរស្រែកយំទ្រហឹងដូចហ៊ុងត្រូវភ្លៀងដើមឆ្នាំ ។ គ្រានោះ មានអាភេទហេតុអាក្រក់បណ្ដាលឲ្យឃើញម្ដងទៀត មើលទៅពួកពលទាហានឃើញសុទ្ធតែកំបុតក្បាលអស់ មានតែកនឹងខ្លួន, ពពកត្រឡប់ក្លែងទៅជារូបបិសាចមាយាសម្ដែងអាការជាទាហាន កំពុងច្បាំងតតាំងគ្នាគគ្រឹកលើផ្ទៃអាកាសមុខគួរឲ្យស្ញែង, មួយស្របក់ឃើញរថសឹកបាក់ខ្ទេចខ្ទី ទង់ជ័យរបស់ចោមពល ក៏ធ្លាក់សំយាកមកដល់ដី, ពលសេហ៍ស្លាប់ត្រៀបត្រាជាហេតុអស្ចារ្យ ឃើញច្បាស់ទៃងនឹងចក្ខុ ។

ទុរយោធន៍ កាលបានឃើញហេតុដូច្នោះ បណ្ដាលឲ្យមានព្រះទ័យរន្ធត់ស្ញប់ស្ញែង មិនទុកចិត្តក្នុងការសង្គ្រាមថានឹងមានជ័យជម្នះ ទើបទ្រង់ត្រាស់ប្រាស្រ័យនឹងភីស្មៈម្ដងទៀត «ទ្រង់ត្រូវទុកដាក់តំណែងរបស់ទ្រង់ ឲ្យទៅកណិកំលោះធ្វើការជំនួសទ្រង់វិញ ខ្ញុំសង្ស័យនឹងព្រះទ័យទ្រង់ ឬព្រះហស្តព្រះបាទរបស់ទ្រង់ វាដូចម្ដេចទៅហើយ ?» ។



ភីស្មៈ ឆ្លើយដោយព្រះសូរសៀងក្រេវក្រោធទៀតថា ៖

«ទុរយោធន៍អើយ ! សេនានុភាពរបស់ទ្រង់ អាចតស៊ូនឹងធម្មានុភាពរបស់បាណ្ឌពបានដែរឬ ការមានជ័យក្នុងសង្គ្រាម មិនមែននៅត្រង់មានសេហ៍ពលច្រើន, មានទាហានកំលោះកម្លាំងកាយមាំមួន ឬក៏ប្រាជ្ញឈ្លាសវៃលាយឡំទៅដោយឧបាយដ៏វៀចកោងនោះទេ, របស់ទាំងនេះនឹងយកមកតស៊ូអានុភាពនៃធម្មៈមិនបានទាំងអស់ មនុស្សដូចយ៉ាងកណិតឲ្យរាប់ម៉ឺន ក៏មិនអាចនឹងយកជ័យជម្នះនៃធម្មៈបានដែរ» ត្រាស់តែប៉ុណ្ណេះហើយ ភីស្មៈក៏បររថសឹកចូលលុកវាយសត្រូវម្ដងទៀត បានចូលបង្រុសលុកលុយទៅក្នុងកងទ័ពធំនៃបាណ្ឌពដែលមកតយុទ្ធ វាយត្រឡប់ត្រឡិនព្រាត់ព្រាយ រត់ជ្រកដោយកៀនកោះ លែងជុំគ្នាជាកងជាក្បួនអស់ ពលដែលស្លាប់ក៏ច្រើនណាស់ឥតបើនឹងគណនាបាន ។ ពួកបាណ្ឌពនឹងទប់ទល់ថ្វីដៃភីស្មៈមិនបាន ក៏ដោះដៃថយក្រោយគ្រាកចេញទៅសិន ។ លទ្ធផលនៃការសង្គ្រាម នៅមិនទាន់ដាច់ស្រេច ជួនជាដល់ពេលរត្តិសម័យ កងទ័ពទាំងពីរខាងបានផ្ដុំត្រែសញ្ញា នាំគ្នាចូលសម្រាកកម្លាំងក្នុងបន្ទាយរៀងខ្លួន ។

ព្រឹកឡើងថ្ងៃទី ៤ នៃការសង្គ្រាមមកដល់ទៀត ទ័ពទាំងពីរពួកបានរៀបចំកងទ័ពជាក្បួនចេញទៅកាន់ទីយុទ្ធភូមិដូចថ្ងៃមុនៗ ដែលបានតតាំងច្បាំងគ្នា ៣ ថ្ងៃរួចមកហើយ មិនទាន់ឃើញខាងណាមានប្រៀបជាងខាងណានៅឡើយ គ្រាន់តែវាយទៅវាយមក ពួនចុះពួន

ឡើង បានផលត្រឹមតែធ្វើឲ្យពេហ៍ពលសកលយោធាស្លាប់ប្រពាក់ប្រពូនរាល់គ្នាដូចជាគេបាល ក្បាលដាច់ចេញពីស្មា រមៀលដូចដុំដីដុំថ្មតែប៉ុណ្ណោះ ។

ថ្ងៃទី ៤ នេះ តដៃគ្នារវាងវីរបុរសភីស្មៈ និងអរជុន អ្នកចម្បាំងឯកទាំងគូនេះ បានចូលប្រយុទ្ធគ្នាហើយ ប្រយុទ្ធទៀត អ្នកម្ខាងថយទៅ អ្នកម្ខាងសង្ក្រុយចូលជិតមក គ្រាន់តែក្រឹតទៅក្រឹតមកយ៉ាងនេះ អស់ពេលជាយូរមើលទៅអ្នកចម្បាំងទាំងពីរនេះ ហាក់ដូចជាព្រះម្ចាស់ប្រទានចំណែកកម្លាំងឲ្យស្មើៗគ្នា មានកម្លាំងប៉ុនគ្នាល្មមប្រឡងគ្នាបាន ។ បន្តិចភីស្មៈថយមួយជំហានទៅ បន្តិចអរជុនថយមួយជំហានទៅ ក្រោយមកម្តង ឃើញដូចជាភីស្មៈឈ្នះ រួចពីនេះឃើញដូចជាអរជុនឈ្នះវិញម្តង ផ្លាស់គ្នាមានប្រៀបម្តងម្នាក់រៀងរហូតទៅ ។ ក្នុងថ្ងៃទី ៤ នេះ បានឃើញមុខមាត់នៃការចម្បាំងពីព្រឹកដល់ថ្ងៃត្រង់ដូចបានរៀបរាប់មកនេះ ។

លុះដល់ពេលរសៀលថ្ងៃដដែលនេះ ភីមសម្តែងមហិទ្ធិឫទ្ធិដ៏មហិមាដូចខ្យល់ព្យុះបក់បោកក្ងួចមកត្រូវ បោលសម្រុកចូលទៅក្នុងកណ្តាលកងទ័ពកុរុម្តងហើយម្តងទៀត ដើម្បីនឹងកាច់បំបាក់កម្លាំង ប៉ុន្តែមិនបានសម្រេចដូចបំណង គ្រាន់តែបានផ្ញើរបួសទុកឲ្យទុរ-យោធន៍ និងសល្យរាជទាំងពីរអង្គបន្តិចម្នាក់ ។ អនុជរបស់ទុរយោធន៍ ១៤ អង្គរួមកម្លាំងគ្នាតម្រង់ចូលជួយព្រះជេដ្ឋា ដើម្បីនឹងកាច់កម្លាំង



ភីមតែម្នាក់ឯង ប៉ុន្តែគ្រាន់តែមកពោម ៗ ហើយក៏ថយចេញអស់ទៅ ។ ភីមប្រហារសម្លាប់អស់ ៨ អង្គ ក្រៅអំពីនេះគេចខ្លួនបាត់អស់ទៅ ។

ក្នុងភាគម្ខាងនៃស្នាមយុទ្ធ អ្នកចម្បាំង ៣ រូប គឺក្រិបាចារ្យ, ទោណា និងសាលី ព្រួតគ្នាចូលវាយអរជុនតែម្នាក់ឯង ប៉ុនប៉ងនឹងគ្រញេចអរជុនឲ្យខ្ទេចនឹងដៃ តែអរជុនគេចរួចអំពីអន្ទាក់នៃអ្នកទាំង ៣ ។ ផែនការសង្គ្រាមក្នុងថ្ងៃនេះ គឺរួមកម្លាំងគ្នាជាពួកជាកង ហើយចូលធ្វើការដណ្តើមយកជ័យជម្នះ ប៉ុន្តែត្រូវវាយទម្លាយកងនោះ ៗ បែកខ្ចាយទៅទាំងពីរពួកដូចគ្នា ។ ក្នុងថ្ងៃទី ៤ នេះ ពួកបាណ្ឌព ស្ងួម្បីត្រូវគេវាយច្រងាប់ច្រងិលដល់ម្លោះក្តី ក៏គង់តែការពាររក្សាខ្លួនបានដែរ មិនដល់នៅការបរាជ័យឡើយ ។ ជួនដល់ពេលត្រូវបិទឆាក ហើយរាត្រីសម័យក៏ចោលស្រមោលមកដល់ ត្រូវឈប់ច្បាំងតាមទំនៀម ។

យុទ្ធវារៈទី ៥ នៃការសង្គ្រាមបានភ្លឺច្បាស់ហើយ ទាហានក្រុមភ្លេង ក៏ផ្លុំត្រែស័ង្ខជាអាណត្តិសញ្ញារៀបចំក្បួនទ័ពនឹងលើកព្យុហៈទៅកាន់ទីយុទ្ធភូមិ ។ កងទ័ពទាំងពីរពួកបានលើកចេញចាកបន្ទាយរៀងខ្លួន ដោយក្បួនយ៉ាងសង្ហាទៅកាន់ស្នាមយុទ្ធ បីដូចជាយាត្រាទៅលេងក្នុងការសប្បាយណាមួយ ។

របៀបច្បាំងដោយ «រួមកម្លាំង» ដែលពួកកោរពចាប់ផ្តើមធ្វើឡើងពីថ្ងៃមុន ។ នៅថ្ងៃទី ៥ នេះ ពួកបាណ្ឌពគិតយកបែបនេះ

មកប្រើភីម និងអរជុន រួមកម្លាំងគ្នាជាមួយកងពលចូលវាយសឹក ។ ទុរយោធន៍ដឹងការទាន់ ដោះដៃគេចចេញអំពីមុខបងប្អូនពីរនាក់នោះ បណ្ដោយឲ្យទោណាចារ្យមករងតដៃជាមួយបងប្អូនពីរនាក់។ ទោណជាគ្រូរបស់ភីម និងអរជុន សិស្សទាំងពីរនាក់នេះនឹងរំលាងគ្រូ ដោយក្របីនោះមិនបានទេ សូម្បីចូលក្នុងសង្គ្រាមប្រើច្បាប់អាជ្ញាសឹកហើយក៏ដោយ ក៏នៅតែធ្វើគ្រូមិនបានដែរ ។ នេះជាឧបាយកលយ៉ាងឯករបស់ពួកកោរពដែលគេចាត់លោកគ្រូឲ្យមកតស៊ូនឹងកូនសិស្សឯង ។

ចំណែកឯអ្នកចម្បាំងកំលោះមួយគូ ដែលតស៊ូគ្នាពីថ្ងៃម្សិលនោះ នៅថ្ងៃនេះគេក៏បានមកជួបប្រទះគ្នាម្ដងទៀតគឺ អភិមន្យុ និងលក្ស្មណម៉ន បានប្រយុទ្ធគ្នាតតូជាច្រើនម៉ោង គេមិនអាចនឹងទាយបានថា អ្នកណាឈ្នះ អ្នកណាចាញ់ឡើយ ប៉ុន្តែក្នុងទីបំផុត ទុរ-យោធន៍ ឈានចូលមកជួយលក្ស្មណម៉ន មិនយូរប៉ុន្មាន ទុរយោធន៍ត្រូវនឹងអាវុធរបស់អភិមន្យុ មានស្លាកស្នាមរបួសជាយ៉ាងដំណំ ទាល់តែគេលើកដាក់ក្នុងអង្រឹងសែងចេញពីទីចម្បាំងទៅ ។ ឯអភិមន្យុកាលបើមានជ័យដូច្នេះហើយ ក៏ចូលទៅគាល់យុធិស្ឋិរ ។

រួចពីនោះបន្តិចមក អភិមន្យុក៏កម្រើកឫទ្ធិក្អេងក្អាងដោយសារខ្លួនមានជ័យជម្នះ បោលសម្រុកទៅរកភីស្មៈទៀត ដោយបំណងនឹងកាច់សឹកកុរុឲ្យបរាជ័យអស់រលីងធេងទៅ ។ ភីស្មៈបានឃើញអភិ-មន្យុចូលមកដល់ក៏ញញឹមពព្រាយ ហើយនិយាយថា «កូនក្មេង



អើយ ! យើងស្ដាយណាស់ដែលទារកតូច ត្រូវព្រាត់ប្រាសអំពីទ្រូងម្ដាយជាយ៉ាងឆាប់ ប៉ុន្តែល្មើយចុះ យើងឲ្យអភ័យទុកជីវិតឲ្យវាម្ដងចុះ» និយាយបានតែប៉ុណ្ណោះ ក៏ជូនវេលាឈប់ច្បាំង ត្រែ ស័ង្ខ ឮជាសញ្ញាឲ្យថយទ័ព ទីសមរភូមិស្ងាត់ជ្រៀប លែងឮសូរសន្ធឹកពាយុនៃចម្បាំង។

លុះដល់អរុណរះឡើងជាថ្មីទៀត ចូលក្នុងថ្ងៃទី ៦ កងទ័ពទាំងពីរខាង បានលើកចេញទៅប្រទល់ប្រទះគ្នានៅកន្លែងដដែល ចូលតយុទ្ធគ្នាយ៉ាងម៉ឺងមាត់ឥតគិតស្ដាយជីវិតសោះ ។ អ្នកចម្បាំងយ៉ាងសំខាន់ សម្រាប់ថ្ងៃទី ៦ នេះ មានភីម ម្ខាង និងអស្វត្ថាម៉ន, សុសរម៉នម្ខាងទៀត ចេញប្រយុទ្ធគ្នាកណ្ដាលរណរង្គ ។ ការសង្គ្រាមបានប្រព្រឹត្តទៅជាខ្មាំងសត្រូវនឹងគ្នាខំប្រឹងដណ្ដើមយកជម្នះតែសព្វខ្លួន។ ប៉ុន្តែការជោគជ័យនៅជាពាក់កណ្ដាលនៅឡើយ ។

បន្ទាប់អំពីនោះមក មានរឿងចម្លែកម្យ៉ាង គឺដោយហេតុតែជឿកម្លាំងរបស់ខ្លួនខ្លាំងពេក ភីមបានរុករានទន្ទ្រានចូលទៅក្នុងកងទាហានជួរមុខដ៏ក្រាស់របស់កងទ័ពកុរុ ពួកកោរពចោមរោមព័ទ្ធជិតជុំវិញខ្លួនភីមព្រួតគ្នាវាយស្ទើរតែនឹងបរាជ័យចាញ់ដៃគេទៅហើយ ប៉ុន្តែឯកម្លាំងកាយ និងចិត្តរបស់ភីមមិនបានថមថយតក់ស្លុតរន្ធត់ដល់បន្តិចសោះឡើយ ។ ភីមថ្លែងសររះជុំវិញខ្លួនត្រូវទាហានបច្ចាមិត្រស្លាប់ខ្លះ គ្រាន់តែរបួសរត់រួចទៅខ្លះ ចេះតែខំតដៃជាប់រហូតឥតឈប់

លែងគិតស្តាយជីវិត ផ្សិតផ្លាក់ខ្លួននៅក្នុងទីចង្អៀត ។ ឯកម្លាំងរបស់ភីមស្មើនឹងកម្លាំងមនុស្ស ១០ នាក់ គ្រានេះការប្រយុទ្ធគ្នាចេះតែទ្វេខ្លាំងឡើងជាច្រើនភាគ មុខគួរឲ្យសម្បើមអស្ចារ្យណាស់ ។ សេចក្តីបំណងរបស់ភីមប៉ុនប៉ងនឹងសម្លាប់ ឬចាប់ទុរយោធន៍ឲ្យបានទាំងរស់តាមពាក្យប្តេជ្ញាពីកាលមុន ប៉ុន្តែគ្រាន់តែបានដូចប្រាថ្នាបន្តិចបន្តួច ត្រង់ផ្ញើស្នាមរបួសទុកនៅរាងកាយទុរយោធន៍ ព្រោះហេតុនោះ ព្រះបាទកុរុជាអ្នកអបហំការ ទើបមិនអាចនឹងចូលធ្វើការប្រយុទ្ធដណ្តើមយកជ័យជម្នះក្នុងពេលនេះបាន។

ក្សិណនោះ ភីមបាត់មុខអំពីថៃវទាហានពួកបាណ្ឌពទៅ ។ យុធិស្ឋិរ កាលរកមើលប្អូនមិនឃើញនៅក្នុងស្នាមយុទ្ធភាគខាងខ្លួន ក៏ឲ្យនឹករសាប់រសល់ឆ្ងល់ក្នុងព្រះទ័យទើបត្រាស់បញ្ជាឲ្យធ្ឫស្តទ្យុម័នទៅតាមរក ។ ធ្ឫស្តទ្យុម័នទៅតាមមិនទាន់ជាឆ្ងាយប៉ុន្មាន ក៏ឃើញរថសឹករបស់ភីម ចតឈប់ស្ងៀមនៅកណ្តាលស្នាមយុទ្ធខាងភាគម្ខាង គ្មានមនុស្សម្នាក់នៅលើរថនោះសោះ ។ ធ្ឫស្តទ្យុម័នបារម្ភព្រួច លុះបានចូលទៅដល់រថហើយ នាយសារថីទូលថា «ភីមមានជីវិតរស់នៅឡើយទេ ឥឡូវនេះកំពុងតយុទ្ធកណ្តាលពួកទាហានកុរុ» ។ នាយសារថីទូលតទៅទៀតថា «មានទាហានសេះមួយពួក មកចោមរោមព័ទ្ធរថភីម បានជាភីមលោតចុះអំពីរថទៅ ដើម្បីនឹងប្រើដៃជើងឲ្យបានស្រួលដូចចិត្ត បានក្របែលទាហានម្នាក់ទម្លាក់អំពីខ្នងសេះ



ហើយលោតឡើងជិះសេះនោះ បរបំដាយចូលទៅវាយខាងចុងទ័ពកុរុ»។ ក្រៅពីពាក្យនាយសារថីទូលនេះ ធ្ឫស្តទ្យុម័ន បានឃើញច្បាស់នឹងភ្នែកខ្លួនឯង គឺឃ្លាតទៅឆ្ងាយអំពីទីដែលទ្រង់ឈរនោះ ទ្រង់ទតទៅឃើញដៃភីមកំពុងតែវាត់ឆ្វេងគ្រវាសស្តាំ និងខាងមុខខាងក្រោយច្របល់គ្នា ឥតមានស្រាកសោះ ។ ប៉ុន្តែភីមប្រហែលជាមិនដឹងខ្លួនធ្លាក់ទៅជាប់នៅក្នុងទីប្រជុំភយន្តរាយដ៏ពន្លឹកដល់ម្លោះទេ ។ ដើម្បីនឹងជួយជម្រុញចិត្តរបស់ភីមឲ្យច្រឡោតស្ទុះឡើងនោះ ធ្ឫស្តទ្យុម័នក៏ស្រែកបន្ទរអំពីចម្ងាយទៅថា «ចូរខំប្រឹងច្បាំងតទៅទៀតចុះ អ្នកចិត្តក្លាអើយ ! យើងមកនៅជិត ៗ នេះស្រាប់ហើយ»។ សម្រែករបស់ធ្ឫស្តទ្យុម័ន នេះមិនដឹងជាភីមបានឮដែរ ឬមិនបានឮទេ ។ លំដាប់នោះមានទ័ពមួយកង លើកតាមធ្ឫស្តទ្យុម័ន ទៅដល់ ហើយបានចូលទៅជួយឲ្យភីមមានប្រៀបមួយរំពេច វាយកងសឹកដែលកំពុងចោមរោមភីមនោះឲ្យបែកបាក់ខ្ចាត់ខ្ចាយអស់ទៅ ។

## ភាគទី ១៣

# សេចក្ដីទោមនស្សរបស់ ទុរយោធន៍

ទុរយោធន៍ សំគាល់ថាខ្លួនជាបុរសជាតិយ៉ាងខ្ពង់ខ្ពស់ស្មើនឹងទេវតាមួយអង្គដែរ គ្រានេះត្រូវរបួសនឹងអាវុធមិនសូវជាធ្ងន់ប៉ុន្មានទេ ប៉ុន្តែអាការៈដែលទ្រង់ថ្ងូរបម្រះនឿលនោះ ឃើញថាជាអាការៈទុរន់ទុរាណក៏ស់ ហាក់ដូចជាដាច់ជីវិតចេញពីរាងកាយ ទាំងនេះមិនមែនដោយឈឺចាប់មុខរបួស ដែលត្រូវនឹងអាវុធនោះទេ មកពីឈឺចិត្តនឹងរឿងដែលទ្រង់ក្រអឺតក្រអោងបោ៉ងហួសប្រមាណ ទាល់តែត្រូវសររបស់គេ រឿងនោះមកប៉ះពាល់ដល់ព្រះហឫទ័យធ្វើឲ្យទ្រង់មួហ្មងជាងខូចដៃ ឬជើងម្ខាងទៅទៀត ។ មានបរិវារមួយពួកបានហែហាមអមអង្គក្នុងខណៈដែលទ្រង់យាងទទ្រេតទទ្រោតត្រឡប់ទៅបន្ទាយវិញ កាលយាងចូលដល់ព្រះពន្លាហើយ ក៏ទម្លាក់អង្គលើកម្រាលផ្ទំស្ដូកស្ដឹង ហាក់ដូចជាប្រុងប្រៀបនឹងធ្វើមរណកាល ទ្រង់រង់ចាំមើលផ្លូវភីស្មៈ ដោយសេចក្ដីក្រវល់ក្រវាយ ដើម្បីនឹងបាននិយាយការសំខាន់ម្យ៉ាង ៗ ។ កាលលោកមេទ័ពចាស់នោះមកដល់ហើយ ទ្រង់ដកដង្ហើមធំត្រាស់ថា «ភីស្មៈ ! ខ្ញុំស្លាប់ហើយណ៎ា ! បង់គំនិតហើយយើង! ពួកបាណ្ឌព គេមានប្រៀបជាងយើងគ្រប់ផ្លូវ» ។

ភីស្មៈឆ្លើយតបដោយសំដីផ្អែមល្ហែម ដូចបិតាស្រឡាញ់បុត្រថា



«កុំអាលសិន! ទ្រង់កុំនិយាយដូចកូនក្មេងយ៉ាងនេះឡើយ របួសបន្តិចបន្តួចប្រហែលនឹងរបួសកូនក្មេង ដែលវារពីសប៉ះទង្គិចនោះប៉ុណ្ណឹង គ្រាន់តែយកទឹកក្ដៅលាងហើយរុំសំពត់ទៅ ក៏វាសះជាហើយ» ។

ទុរយោធន៍ «ខ្ញុំឈឺចិត្តណាស់ ដោយឃើញពួកបាណ្ឌពមានជ័យ» ។

ភីស្មៈ «ហ្នឹងជាសេចក្ដីឃើញខុសឆ្ងាយអំពីការពិត ដូចគ្នានឹងសេចក្ដីយល់ឃើញខាងដើមនៃការសង្គ្រាម កាលពីរបីថ្ងៃកន្លងទៅហើយនោះ ទ្រង់បានធ្វើការភ្លាំងភ្លាត់ខ្លួនឯង ដោយស្មានកម្លាំងពួកបាណ្ឌព ថាខ្សត់ខ្សោយណាស់ ឥឡូវនេះទ្រង់ភ្លាំងភ្លាត់ស្មើរតែធ្វើការមិនកើតទៀត ដូចយ៉ាងការដែលកន្លងហួសទៅហើយ ស្មានការខូចខាតរបស់ទ្រង់ច្រើនតែហួស ៗ ខុស ៗ មិនទាន់ដល់ម្ល៉ោះទេ តាមដែលពិនិត្យមើលទៅឃើញថា កងទ័ពយុធិស្ឋិរ មានមេទ័ពអ្នកមានថ្វីដៃពូកែ ៗ ជាច្រើនអ្នកមែន ប៉ុន្តែតាំងអំពីនោះរហូតមកដល់ឥឡូវនេះ គេក៏មិនទាន់មានប្រៀបអ្វីឲ្យជាដុំកំភួនជាងយើងដែរ កុំអាលខ្លាចថ្វី ការខ្លាចខូចខាតជ្រុលពេក ដោយមិនបានត្រិះរិះឲ្យមាំមួន ធួននឹងហេតុផល នឹងនាំឲ្យកើតទោសច្រើនជាងការខូចខាតមែន ៗ» ។

ទុរយោធន៍ស្ដេចចូលក្រឡាបន្ទំ ទ្រង់សោយទុក្ខវេទនាឈឺចាប់ស្នាមរបួស ថែមទាំងព្រះទ័យអណ្ដែតអណ្ដូង រាយមាយទៅតែក្នុងរឿងសឹកសង្គ្រាមផងទៀត ក្នុងរាត្រីនោះ ទ្រង់ឥតបានផ្ទំស្កល់ដល់

បន្តិចសោះ ។ រាត្រីកាលដែលកន្លងទៅសន្សឹម ៗ ទម្រាំតែគ្រប់ ៣ យាម ឃើញថាយឺតយូរខ្លាំងណាស់ ហាក់ដូចជាសេចក្ដីឈឺចាប់ដែលប្រចាំនៅក្នុងខ្លួនតែងមានយ៉ាងនេះ រៀងរហូតដល់អស់អាយុ ។

ផ្កាយព្រឹករៀងរះត្រចះឡើង កំចាត់យប់យាមរាត្រី សកុណជាតិយាសយំប្រចាំយាមជិតភ្លឺ បីដូចជាតៀវនអរុណ ឲ្យឧទ័យរៀងរះភ្លឺព្រាងស្វាងឡើង ទុរយោធន៍មានសំពត់រុំរបួសថ្មី ៗ បានស្ដេចនាំទ័ពចូលក្នុងស្នាមយុទ្ធដោយឥតគិតដល់អាការរោគ ដែលឈឺចាប់ក្នុងព្រះអង្គ ។

ភីស្មៈទ្រង់តំណែងជាមេទ័ពធំ ទ្រង់ចាត់ក្បួនទ័ពកុរុជាព្យុហយាត្រាយ៉ាងបែបថ្មីដើម្បីដណ្ដើមយកជ័យជម្នះ ដែលខូចខាតទៅក្នុងថ្ងៃមុន ចាត់ក្បួនដំរីជាច្រើនស្រទាប់ ច្រើនជាន់ព័ទ្ធជុំវិញកងទ័ពមានសណ្ឋានដូចជាកំពែងច្រើនជាន់ រៀបរថមេទ័ពមេកងផ្សេង ៗ ទុកនៅខាងក្រោយទ័ពដំរី យកទ័ពដំរីជារបាំង ។ គ្រប់តែរថមានទាហានជិះសេះមួយពួក ៗ ប្រាំពីរ ៗ នាក់ ចាំរក្សាការពារ ។ ទាហានសេះគ្រប់ ៗ រូប មានពលទាហានកាន់ធ្នូ មួយពួក ៗ ចាំការពារ ។ ពួកទាហានធ្នូគ្រប់ ៗ រូប មានពួកទាហានកាន់លំពែងប្រាំពីរ ៗ នាក់ជាពួកកាន់តាមក្រោយ ។

អរជុនក្រឡេកឃើញទ័ពមុខដូចជាកំពែងយាត្រាចូលមក ក៏និយាយនឹងក្រឹស្ណៈ ថា «ទ្រង់ឃើញកងទ័ពកុរុ ឯណោះក្រាស់ច្រើន



ស្រទាប់ច្រើនជាន់ឬទេ ? ប៉ុន្តែបើថៃវទាហានរបស់គេក្រាស់ក្រៃលឡើងដរាបណាក៏រីតតែជាការងាយ យើងនឹងក្រាយឲ្យវាលទៅដរាបនោះ, ទ្រង់សង្កេតឃើញឬទេ ពួកមេទ័ពរបស់គេ បន្លឹមបំបាំងខ្លួនក្នុងវាំងថៃវទាហ៊ាន ៣ ជាន់, មើលចុះ មនុស្សជាតិអ្នកចម្បាំងខ្លាចអីម្ល៉េះ វាប្រយ័ត្នតែលោហិត និងជីវិតរបស់វាទុកឲ្យគង់នៅតែប៉ុណ្ណោះ»។

លំដាប់នោះ អរជុនក៏ដើរសំដៅចូលទៅរកកងទ័ពមុខដែលកំពុងលើកចូលមក ។ ទោណាចារ្យក៏ចេញមកទទួលមុខអរជុន បបួលឲ្យច្បាំងតតួ ព្រោះជាក្សត្រិយ៍ជាតិអ្នកចម្បាំង តែឮត្រង់រឿងចម្បាំងហើយ ឥតមានចិត្តរួញរាប៉ុនសរសៃរោមឡើយ ។ អ្នកចម្បាំងទាំងពីរបានប្រយុទ្ធគ្នាក្នុងភ្លេងយុទ្ធវិធី ទាំងពីរនាក់ក៏សម្ដែងសេចក្ដីក្លាហាន និងសេចក្ដីអំណត់អត់ធន់ រកអ្នកឯណាស្មើគ្មាន ។ សង្គ្រាមគ្រាណាក៏ឥតស្មើនឹងគ្រានេះដែរ ព្រោះគ្រានេះ ជាឱកាសល្អបំផុត ជាឱកាសឲ្យបានឃើញទាហានឯកតស៊ូគ្នា ។

ក្សិណនោះ កូនសរមួយទៅដោតជាប់នៅខ្នងទោណាចារ្យដោយមិនទាន់ដឹងខ្លួន ។ ទោណាចារ្យក្រឡេកមើលឃើញព្រះរាជាសង្ខៈដ៏ជារាជសម្ព័ន្ធមិត្ររបស់យុធិស្ឋិរ ក៏ឆុរឆេះដោយទោសគ្គិ បែរដាំងទៅបាញ់ព្រះរាជាសង្ខៈទិវង្គតនៅនឹងកន្លែងនោះមួយរំពេច ។

ព្រះបាទសង្ខរាជទិវង្គតនៅចំពោះមុខអរជុនដូច្នោះ ធ្វើឲ្យអរជុនឈឺចិត្តគិតរកផ្លូវកែកំហឹងឲ្យបានវិញ ទើបដកដៃចេញអំពី

ទោណាចារ្យដែលទ្រង់ជ្រាបថា ជាអាចារ្យសម្លាប់មិនបាន ស្ទុះស្លោ ចូលទៅរកសុសរម័ន ដែលទ្រង់ចាំបានថាធ្លាប់ធ្វើជាមេទ័ពលើកទៅ គំរាមព្រះបាទវិរាជគ្រាដំបូងម្តង ឯចំណេះវិជ្ជាក្នុងផ្លូវយុទ្ធវិធីរបស់ សុសរម័ននោះ មិនល្មមនឹងមកទប់ទល់កម្លាំងថ្មីដៃអរជុនទេ ហេតុ នោះការប្រឡងយុទ្ធគ្រានេះ អរជុនទើបមានប្រៀបមួយរំពេច ដោយ បានវាយសុសរម័នខ្ចាត់ចេញទៅ ក្នុងភ្លេងដំបូង ដែលចូលរះអាវុធគ្នា នោះ ។ ប៉ុន្តែការមានជ័យ និងបរាជ័យទាំងអម្បាលនេះគ្រាន់តែជា ភាគបន្តិចបន្តួចនៃការសង្គ្រាមប៉ុណ្ណោះទេ ឯជ័យជម្នះយ៉ាងធំធ្លាក់ ទៅនៅក្នុងកណ្តាប់ដៃនៃភីស្មៈក្នុងថ្ងៃទី ៧ ព្រោះ ភីស្មៈ ធ្វើការចម្បាំង យ៉ាងម៉ឺងមាត់ណាស់ គ្មានអ្នកណានឹងអាចទប់ទល់បានឡើយ ទាល់ តែពួកបាណ្ឌពបាក់បែកខ្ចាត់ខ្ចាយអស់ សូម្បីភីម និងអរជុនដែលអ្នក រាល់គ្នាធ្លាប់ដឹងហើយថារឹងឫទ្ធិបំផុតនោះ ក៏ទើតមិនបានដែរ ។ មុន រាត្រីកាលជិតដល់ពេលព្រលប់ ទង់ជ័យកំពូលទ័ពរបស់យុធិស្ឋិរ ត្រូវ ពួកកោរពកាប់គ្របែលរលំទ្រេលទៅ ។ រត្តិសម័យក៏ងងឹតព្រាងព្រឹល ចូលមកដល់ ។ ត្រែសញ្ញាផ្អាកចម្បាំងបន្លឺសូរស័ព្ទយ៉ាងរូសរាន់ ។ នា រាត្រីយប់នោះ មានការរីករាយសប្បាយជ្រួលជ្រើមក្នុងបន្ទាយកុរុ ដោយឃើញកងទ័ពទុរយោធន៍មានជ័យជម្នះយ៉ាងសម្បើម ។

លុះដល់អរុណោទ័យ បញ្ចេញរស្មីព្រឹកព្រាងស្វាងឡើងហើយ កងទ័ពទាំងពីរពួក បានយាត្រាចូលក្នុងយុទ្ធមណ្ឌល ចូលប្រយុទ្ធ



កាប់សម្លាប់គ្នាឈាមច្រាលស្រពប្រឹថពីទៀត ។

ថ្ងៃទី ៨ នេះ ជាថ្ងៃដែលភីមនឹងសម្តែងកម្លាំងដ៏ខ្លាំងពន្លឹករបស់ ខ្លួន ។ ជ័យជម្នះបន្តិចបន្តួចរបស់ពួកកោរពរាល់លើក ដែលមានមក ហើយនោះ បានធ្វើឲ្យពួកបាណ្ឌពក្តៅក្រហាយចិត្តជាខ្លាំង ។ ឯជ័យ ជម្នះរបស់ពួកបាណ្ឌពរាល់គ្រាក៏ដូចគ្នាដែរ ធ្វើឲ្យភីស្មៈក្រេវក្រោធឆុរ ឆេះយ៉ាងក្រៃលែង បានជាផលនៃសង្គ្រាមឡើង ១ ចុះ ១ យ៉ាងនោះ កើតមកតែអំពី ភីស្មៈ និងភីមទាំងពីរប្រាណ ផ្លាស់ប្តូរគ្នាសម្តែង មហិទ្ធិឫទ្ធិកម្លាំងក្លាហានកណ្តាលស្នាមយុទ្ធ ។ ឯរូបរាងកាយរបស់ ភីមនេះ សូម្បីតែក្នុងវេលាមានអារម្មណ៍ស្ងប់ស្រួល ក៏មើលទៅឃើញ ធំសម្បើមមុខគួរឲ្យស្ញប់ស្ញែងណាស់ទៅហើយ ចំណង់បើដល់ពេល គេមានទោសៈបណ្តាលឡើងទៀត ក៏ស្មើដូចជាគេមានវេហ៍ពលរាប់ ម៉ឺនសែននៅក្នុងខ្លួន ។ ថ្ងៃនេះ ភីមសម្តែងកម្លាំងមហិទ្ធិឫទ្ធិដ៏ខ្លាំង ពន្លឹកនោះទៀត បានចូលវាយកងរយនៃកុរុឲ្យបែកខ្ចាត់ខ្ចាយទៅ ទាំងកង ១ ដោយកម្លាំងតែម្នាក់ឯង ។

ភីស្មៈ និយាយលួងលោមពួកសេនាទាហានដែលគេចរត់ទៅ នោះស្ទើរតែពុំបាន ប្រឹងចំកោងស្រែកទាល់តែអស់សម្លេងថា «ឱកុរុ! យ៉ាងនេះឬសេចក្តីក្លាហានដែលល្បីនាមរបស់កុរុ ? យ៉ាងនេះឬ ប្រពៃណីរបស់អ្នកចម្បាំង ? ដោយសេចក្តីប្រព្រឹត្តយ៉ាងនេះឬហៅថា អាចនឹងរក្សាកេរ្តិ៍ឈ្មោះ នៃបុព្វបុរសរបស់អ្នកបាន ? ចូរមើលចុះ ខ្លួន

យើងបានយកជីវិតរបស់យើងតែម្នាក់ឯង ទៅតស៊ូប្តូរនឹងសឹកដែលមានកម្លាំងច្រើនជាងរាប់ពាន់ម៉ឺនភាគ ខ្លួនយើងតែម្នាក់ឯងក៏អស់កម្លាំងកាយដែរ ទោះបីនឹងបែកភាគពោមរបស់យើង ឲ្យក្លាយទៅជាទាហានកាន់អាវុធចូលទៅប្រយុទ្ធនឹងគេ ក៏គង់តែលំបាកដែរ, ទោះបីដល់ម្លឹងហើយ យើងក៏នៅតែមិនរត់ចេញ» ។ សំដីឃោសនាទាំងនេះបានចូលទៅខ្ទាំងខ្ទប់ហាទយវត្ថុទាហានកុរុពួកក្សត្រិយ៍ គន្ធារី ៦ អង្គបានឮសំដីលោកមេទ័ពដូច្នោះហើយ ក៏កើតមនោមនះឡើងលាន់វាចាថានឹងយកជីវិតឥរាវ័តឲ្យបាន, ទាំង ៦ អង្គទ្រង់សេះសម្បុរដូចទឹកដោះបររហោចដូចហ្វូងហង្សហើរឆ្លងសមុទ្រ ចូលប្រយុទ្ធវាយទ័ពបាណ្ឌពបែកខ្ចាត់ខ្ចាយអស់ នៅសល់តែឥរាវ័ត (បុត្រអរជុន កើតអំពីនាងឧលុបីដ៏ជានាគធីតា) ទទួលតដៃតែម្នាក់ឯងទាល់តែសម្លាប់គន្ធារីកុមារបាន ៥ អង្គដោយលំដាប់មក ។ គន្ធារីកុមារអង្គទី ៦ ជាច្បងនៃកុមារទាំង ៥ ដែលក្ស័យព្រះជន្មទៅ រូបរាងធំមាំដំបង បានចូលប្រយុទ្ធគ្នាតតូ មិនយូរប៉ុន្មាន ក៏ប្រហារសម្លាប់ឥរាវ័តបានវិញ ។

អរជុនបានដឹងថា ឥរាវ័តត្រូវអាវុធស្លាប់ហើយ ក៏កើតទោសោឡើងដូចភ្លើងព្រៃត្រូវពាយុបក់ ឡើងជិះពាជីបរល្បឿនដូចព្រះកាលសំដៅទៅក្នុងកងទ័ពកុរុបង្រុសវាយត្រឡប់ត្រឡិនខ្ទេចខ្ទី ដូចផែនសិលាដ៏ធំធ្លាក់អំពីទីខ្ពស់ទៅទីទាប ធ្វើសេចក្តីវិនាសដល់ពួកកុរុជុំវិញខ្លួន ។



ឃដោត្កចៈជាបុត្រភីម កើតអំពីនាងហិឌិម្ពាជារាក្សសី មានទាហានរួមចិត្តមួយពួកតាមទៅផង រុកចូលទៅក្នុងកណ្តាលចំណោមកងទាហានសឹកដើម្បីនឹងសងមរណៈនៃឥរាវ័ត ។ ទុរយោធន៍ ជាអ្នកនាំទ័ពខ្លោងដំរីចូលបញ្ជាន់ ប៉ុន្តែឃដោត្កចៈ វាយបង្អើលខ្លោងដំរីឲ្យផ្អើលបោលប្រសាចទៅទាំងខ្លោងអស់ទៅ ។ ទុរយោធន៍មិនព្រមគេចរត់ចេញ ធ្លាក់ទៅកណ្តាលសឹកតេងតាងតែម្នាក់ឯង តដៃដោះខ្លួនបណ្តើរថយបណ្តើរ មិនឲ្យសឹកចាប់ខ្លួនបាន ។ ទទួលខណៈនោះមានព្រះរាជាមួយអង្គជាសម្ព័ន្ធមិត្រនឹងទុរយោធន៍ បរដំរីសឹកទៅជួយវាយកាត់រវាងទុរយោធន៍នឹងសឹក គឺឃដោត្កចៈឲ្យគ្រាកចេញទៅ ។ បន្តិចលេចភីស្មៈនាំទ័ពធំស្រូតរូតទៅជួយការពារទុយោធន៍ទៀត ។ ឃដោត្កចៈត្រឡប់ជាផ្លោះការ ធ្លាក់ខ្លួននៅក្នុងកណ្តាលចំណោមវិញ ប្រសិនបើពួកបញ្ចាលមិនប្រញាប់ប្រញាល់លើកកម្លាំងទៅជួយទាន់ការទេ មុខជាគេនឹងចាប់ខ្លួនឃដោត្កចៈបាន ។ សង្គ្រាមក្នុងទី ៨ នេះ នៅមិនទាន់ចប់ស្រេចថាខាងណាមានជ័យ ខាងណាបរាជ័យទេ ។ ចាប់តាំងពីថ្ងៃច្បាំងគ្នាជាដំបូងរហូតមក ដល់ថ្ងៃទី ៨ នេះ បានប្រឹងប្រែងដណ្តើមយកជ័យជម្នះតែរៀងខ្លួន ប៉ុន្តែសឹកទាំងពីរផ្នែកមានកម្លាំងស្មើគ្នា មិនអាចនឹងផ្តាច់ទីយកជ័យម្ខាង ៗ បាន ។ ឯទុរយោធន៍ ទ្រង់ជ្រាបចំនួនទាហានរបស់ព្រះអង្គថា ស្លាប់បាត់បង់ទៅជាយ៉ាងច្រើនដែលសេសសល់នៅឃើញស្តួចស្តើង។ ទុរយោធន៍

ទ្រង់ទោមនស្សតូចព្រះហឫទ័យម្តងទៀត ដោយទ្រង់នឹករអាព្រះហឫទ័យក្នុងរឿងដែលនឹងចាប់ធ្វើការតទៅទៀត ជាយូរ ឬឆាប់ដូចម្តេចជាមិនត្រូវ ។ ព្រះហឫទ័យរបស់ទ្រង់ត្រាំត្រែងចំបែងទៅដោយទុក្ខ ជញ្ជឹងរំពឹងគិតដល់ថ្ងៃដែលកន្លងហួសទៅហើយ ក៏មិនឃើញផលអ្វីមួយចំណិតសោះ ដែលជាទីញ៉ាំងចិត្តឲ្យរីករាយសប្បាយបាន នឹករំពឹងមើលទៅថ្ងៃខាងមុខទៀត ក៏ឥតឃើញផ្លូវណានឹងសង្ឃឹមទុកចិត្តបាន រឿងនេះធ្វើឲ្យទ្រង់តឹងធ្ងន់ព្រះហឫទ័យពន់ពេក ។

ក្បិណនោះ កណិ អ្នកមេបញ្ញាឧបាលកលចូលទៅគាល់ក្នុងបារាំទីគង់របស់ទុរយោធន៍ ចាប់ផ្តើមទូលញុះញង់បំផ្លើសប្រកព្រះកាណ៌ទុរយោធន៍ ឲ្យទ្រង់មានសន្និះសង្ស័យថា «ទូលព្រះបង្គំគ្មានចេតនាបំណង នឹងលុបលាងសេចក្តីសត្យសុចរិតរបស់អ្នកឯណានីមួយដែលព្រះករុណា ទ្រង់ទុកព្រះរាជហឫទ័យយ៉ាងស្និទ្ធឥតរង្កៀសមកយូរហើយនោះទេ ប៉ុន្តែព្រះករុណាក៏ទ្រង់ជ្រាបច្បាស់ឥតសង្ស័យថា បើទុកជាកងទ័ពណាខ្លាំងពូកែដូចម្តេចក្តី ក៏យើងអាចនឹងញ៉ាំងសេចក្តីប្រាថ្នាឲ្យសម្រេចបានដែរ ។ បើអ្នកមេទ័ពនោះ ៗ មកបង្អង់ការ មិនសូវយកចិត្តទុកដាក់ក្នុងរាជការនាទីរបស់ខ្លួន ហើយអ្នកមេទ័ពប្រៀបដូចជាក្បាលរបស់រាងកាយ, សេនាទាហានប្រៀបដូចជាអវយវៈឯទៀត, អ្នកជាមេទ័ពត្រូវតែខំប្រឹងឲ្យរឹងប៉ឹងមាំមួនឲ្យក្លាហានដោយកម្លាំងកាយ និងចិត្ត ដាស់តឿនចិត្តទាហានគ្រប់កង



ក្នុងបន្ទុក បង្គាប់បញ្ជារបស់ខ្លួន ឲ្យមានចិត្តមានះក្នុងការតស៊ូនឹងសឹកសត្រូវ ។ ទូលព្រះបង្គំគិតព្រៃងតែ... ទូលព្រះបង្គំអាចសារភាពក្រាបទូលថា ភីស្មៈមានគំនិតស្ងាត់កំបាំងក្នុងចិត្ត, ការគ្មានសត្យសុចរិតក្នុងចិត្តរបស់មេទ័ពនោះឯងជាឈ្នួនអាវុធ ដែលអាចនឹងញ៉ាំងរាជអាណាចក្រឲ្យលិចលង់វិនាសទៅតែក្នុងមួយពេលជាមិនខាន» ។

ទុរយោធន៍ សម្រឹងស្តាប់ពាក្យឧបាយកលនេះហើយ មានព្រះហឫទ័យវិប្បដិសារក្តៅក្រហាយក្នុងសេចក្តីសង្ស័យដ៏ងងឹតឈឹងដែលទ្រង់ធ្លាប់សន្និះសង្កាមកយូរហើយក្នុងរឿងភក្តីនៃចមពលរបស់ព្រះអង្គ ។ ឯកណិជាមនុស្សសំខាន់ក្នុងរាជការទាហានក៏មានសេចក្តីសង្ស័យយ៉ាងនេះដែរ ជាហេតុធ្វើនូវសេចក្តីងងឹតក្នុងរឿងភក្តីនោះឲ្យភ្លឺច្បាស់ឡើងបន្តិចទៀត ។ ប្រការមួយទៀត កណិជាមិត្រគួររស់គួរស្លាប់ ឬជាមិត្ររួមចិត្តជីវិតមួយរបស់ទុរយោធន៍ ហេតុដូច្នោះពាក្យទូលណែនាំរបស់ កណិរមែងមានទម្ងន់គួរឲ្យជឿបាន ។ កណិបង្អង់និយាយមួយស្របក់ ហើយក៏ចាប់និយាយតទៅទៀតថា «ទូលព្រះបង្គំដឹងហើយថា ភីស្មៈជាមហាបិតុលារបស់ព្រះអង្គ តាមទំនៀមមហាបិតុលា មិនដែលធ្វើឲ្យកូនក្មួយរបស់ខ្លួនវិនាសហិនហោចទេ ប៉ុន្តែព្រះករុណាតោងជ្រាបថាភីស្មៈជាបុព្វបុរសទាំងខាងកុរុទាំងខាងបាណ្ឌព មួយទៀតធម្មតាមនុស្សចាស់រមែងវង្វេងលំអៀង សម្តែងសេចក្តីស្រឡាញ់អើពើរាក់ទាក់ដល់ម្ខាងច្រើនជាងម្ខាង ដ្បិតមនុស្ស

ចាស់រាល់រូបតែងមានកូនមានក្មួយជាទីស្រឡាញ់ពេញចិត្ត នឹងកន្យានារីជាទីស្នេហារបស់គេ ភីស្មៈនឹងបានផុតពីអំណាចកិលេសទាំងនេះទៅហើយក៏ទេដែរ ឯការដែលភីស្មៈសម្តែងសេចក្តីលំអៀងទៅខាងបាណ្ឌពនោះ សង្កេតដឹងបានក្នុងគ្រាប្រឹក្សាស្ងប់សឹក ភីស្មៈទូលធ្មតរាស្ត្រឲ្យលើកឥស្សរភាពប្រគល់ទៅឲ្យបាណ្ឌពវិញ ប៉ុន្តែរឿងនេះមិនបាច់ទូលព្រះបង្គំ នឹងរំលើកមកសម្តែងឲ្យពិស្តារទេ» ។

អរគុណអ្នក ! កណ៌ា យើងអរគុណអ្នកហើយ ! ទុរយោធន៍ឆ្លើយតបហាក់ដូចមនុស្សមើមមាយយល់សប្តិ រួចក៏ស្តេចតួងតាងព្រួសប្រាស ទៅឯបារាំទីសំណាក់របស់ភីស្មៈ ស្រែកសួរថា ខ្ញុំចូលទៅបានឬទេ ?

«អ្នកណាហ្នឹងហ៎ះ ? មកទាំងយប់អធ្រាត្រ ខុសពេលវេលាដូច្នេះ» សម្លេងភីស្មៈស្រែកសួរវិញ ។

«ខ្ញុំ ទុរយោធន៍» ។

«សូមអភ័យទោស ! អញ្ជើញស្តេចចូលមកខាងក្នុង អ្វីវាមកដេញទ្រង់ឲ្យក្រោកចេញអំពីទីបន្ទំទាំងយប់ទាំងអធ្រាត្រយ៉ាងនេះ?»

ខ្ញុំមានសេចក្តីតូចចិត្តណាស់ដែលខ្ញុំមកកំបោកពោកទ្រង់ ក្នុងវេលាចូលដំណេក សេចក្តីគិតមួយរឿងដ៏ធ្ងន់ វាមកសង្កត់ហាទយវត្ថុខ្ញុំ, ខ្ញុំមកនេះដើម្បីរំសាយទុក្ខឲ្យស្រាលទ្រូង »។

«គំនិតផ្តេសផ្តាសចាស់ ៗ របស់ទ្រង់ទៀតទេដឹង ? » ។



«ទេ ! មិនមែនគំនិតផ្តេសផ្តាសទេ ! ខ្មោចអ្វីវាចូល បានជាតាំងពីព្រលប់រហូតថ្មើរនេះ ខ្ញុំដេកឥតលក់សោះ រឿងខ្មោច ៗ នេះឯង វាចូលមកគ្របសង្កត់ចិត្តខ្ញុំ វាធ្វើទុក្ខធ្វើបាបខ្ញុំ» ។

«ចូរទ្រង់មានបន្ទូលមកមើល ប៉ុន្តែសូមអាណិត កុំបញ្ចេញគំនិតចាស់ ៗ មកទៀត ទូលបង្គំនឹងរម្ងាប់ឲ្យផ្ទំលក់បាន» ។

ទុរយោធន៍ «ទ្រង់មិនឃើញទេឬ ? ក្នុងពេលល្ងាច ៗ យើងទន់ប្រៀបជាងគេរាល់ ៗ ថ្ងៃ, ភីស្មៈអើយ ! សេចក្តីប៉ុនប៉ងយកជ័យជម្នះដោយអាស្រ័យកម្លាំង សេចក្តីក្លាហានរបស់ទ្រង់ ដែលកាន់តំណែងជាស្តេចសឹកនៃកុរុ, ពួកបាណ្ឌព គេក្លាហានក្នុងសឹកសង្គ្រាមណាស់ គេចៀសវាងផុតអំពីកណ្តាប់ដៃទ្រង់ ដែលប្រកបដោយប្រជិពលហើយគេប្រហារកងទាហានរបស់ទ្រង់ឲ្យបែកខ្ញែកព្រាត់ព្រោងរាល់អន្លើ, ចូររឭកនឹកដល់ពាក្យប្តេជ្ញារបស់ទ្រង់ដែលថា «នឹកគាំពារត្រកូលខត្តិយរាជក្រុងហាស្តិនបុរទុកឲ្យគង់វង្សបាន» សូមទ្រង់ឲ្យអភ័យក្នុងពាក្យដែលមិនគួរគប្បីរបស់ខ្ញុំ ថាបើក្នុងហាឫទ័យរបស់ទ្រង់ត្រូវសេចក្តីមេត្តាដល់ពួកបាណ្ឌព ចូលទៅគ្របសង្កត់ហើយសោតក៏ចូរឲ្យកណ៌ាទទួលនាទីជាអ្នកនាំទ័ពរបស់យើងជំនួសទ្រង់ចុះ នឹងបានធ្វើការឲ្យបានជ័យជម្នះជាឆាប់ ៗ ទៅ» ។

ភីស្មៈដកដង្ហើមធំ ហើយឆ្លើយថា «អនិច្ចាទុរយោធន៍ ! សេចក្តីសំគាល់របស់ទ្រង់នោះ មិនបានជាផលប្រយោជន៍អ្វីទេ, ការសង្គ្រាម

របស់ទ្រង់នេះជាការឥតស៊ូឥតផល, សេនាទាហានរេហ៍ពលរបស់ទ្រង់ស្មើហាក់គ្រឿងប្រដាប់សម្រាប់កូនក្មេងវាលេង ឥតតម្លៃក្នុងកណ្ដាប់ដៃនៃកម្មពៀរ ខ្ញុំទូលប៉ុន្មានដងរួចមកហើយថា «សេចក្ដីជាធម៌នឹងឈ្នះ, អ្នកដែលច្បាំងដើម្បីទ្រទ្រង់នូវធម៌ មានអាវុធទ្វេជាពីរភាគនៅក្នុងខ្លួន, ចំណែកការច្បាំងជាអធម៌ រមែងមូលបង្វិលកម្លាំងរបស់ខ្លួនឯងឲ្យវិលចូលមកទម្លាយបំផ្លាញនូវខ្លួនឯងវិញ, ទ្រង់ភ្លេចហើយឬនៅ ? កាលដែលយើងលើកកងទ័ពទៅវាយដណ្ដើមប្លន់យកហ្វូងសត្វពាហនៈនៅទីវាលមច្ឆនគរក្រុងដែនវិរាជនោះ គ្រាន់តែអំណាចនៃសេចក្ដីក្លាហានរបស់អរជុនម្នាក់ឯង រេហ៍ពលរបស់ទ្រង់ទាំងទ័ពនាំគ្នារត់ព្រាតរបស់គេ ។ មួយទៀតទ្រង់ភ្លេចហើយឬនៅ ? កាលពីដើមពួកគន្ធារពចាប់ទ្រង់បាននាំយកទៅបាន អរជុនតែម្នាក់ឯងទេតើ ដែលក្លាហានចូលទៅកាច់គ្រឿងពន្ធនាគារ ដោះយកទ្រង់រួចមកវិញ អរជុននេះមានជីវិតរស់នៅក្នុងពួកបាណ្ឌពនៅឡើយ គ្រានេះ គេបានក្រឹស្ណៈមកធ្វើនាទីជានាយសារថីរបស់អរជុនទៀតផងទាំងទ្រង់ក៏ធ្លាប់បានជ្រាបស្រាប់ហើយថា ក្រឹស្ណៈជាបុរសជាតិមានទេវតាមួយអង្គនៅគ្រប់គ្រង់ខ្លួនគេ រឿងនេះវាកើតប្រាជកដល់ភ្នែកយើងព្រិល ៗ ខ្លះដែរហើយ, ទុរយោធន៍ ព្រះអង្គត្រូវប្រកាន់យកព្រហ្មលិខិតក្នុងការសង្គ្រាមគ្រានេះ ហើយបើភីស្មៈនៅមានជីវិតដរាបណានឹងធ្វើមុខការរបស់ខ្លួនដោយសត្យសុចរិតដរាបនោះ ប៉ុន្តែ



មរណៈរបស់ភីស្មៈ កាន់តែសស្បៀរចូលមកជិតខ្លួនណាស់ហើយ ទ្រង់កុំព្រួយថ្វីឡើយ បើមរណៈមកដល់ខ្លួនទូលបង្គំហើយ ចាំទ្រង់ឲ្យអ្នកធំឯណាទៀត ចូលមកគ្រប់គ្រងនាទី ជាអ្នកបញ្ជាការកងទ័ពកុរុតទៅចុះ ប៉ុន្តែខ្ញុំសុំថ្លែងបញ្ជាក់ម្តងទៀត ឲ្យទ្រង់ជ្រាបថា ការសង្គ្រាមកុរុក្សេត្រគ្រានេះ នឹងឲ្យផលដល់បរាជ័យរបស់បដិបក្ខ គឺមុខជាច្បាំងចាញ់គេហើយ» ។

លុះដល់ព្រឹកឡើងជាថ្ងៃគំរប់ ៩ កងទ័ពទាំងពីរផ្នែក ក៏លើកចេញទៅធ្វើការប្រយុទ្ធគ្នាដូចថ្ងៃមុន ៗ ទៀត ។ ព្រះភីស្មៈឡើងក្រញូវក្រញីងខឹងក្រោធព្រះនេត្រល្បឿនច្រឡោតស្មើរស្រក់លោហិតដោយគិតនឹកដល់ពាក្យកោសរូសរបស់ទុរយោធន៍ ហេតុដូច្នោះនៅថ្ងៃនេះ គេទើបប្តូរចម្បាំងដោយកម្លាំងទោសៈលែងខ្លាចស្លាប់ ។ តាំងពីព្រឹកដល់ថ្ងៃត្រង់ ពីថ្ងៃត្រង់ដល់រសៀល គ្មានអ្នកណានឹងទប់ទល់វីរបុរសនេះបានឡើយ ។ ពួកបាណ្ឌពនាំគ្នារត់ប្រសាចទៅខាងមុខគេដូចហ្វូងម្រឹគ ។ រថសឹកភីស្មៈដែលគ្មាននរណាទប់ទល់បាននោះ ក៏បរបង្រ្កុសសម្រុកពុះពារលើសពទាហានដែលស្លាប់ នឹងដែលត្រូវរបួសកំពុងតែត្រដាបត្រដួសជិតស្លាប់ត្រៀបត្រាដូចគេហាល សំដៅទៅរកពួកទាហានដែលកំពុងតែប្រយុទ្ធគ្នា នឹងពួកដែលគេចរត់ទៅគ្មាននរណាទើតទើសមុនបាន រហូតដល់យប់យាមសន្ធយារាត្រីកាលចូលមកដល់ ។

យុធិស្ឋិរ អ្នកទ្រង់សីល ក៏ទោមនស្សតូចព្រះរាជហឫទ័យ
ពន់ប្រមាណ ដោយបានទតឃើញទីយុទ្ធភូមិដីស្រពស្រោចដោយ
លោហិតទាហានដែលត្រូវអាវុធស្លាប់ និងត្រូវរបួសជិតស្លាប់ ប្រាល
ក្រាលពេញប្រឹថពី ព្រះហឫទ័យដ៏ទន់របស់ទ្រង់ ស្ទើរតែនឹងទ្រាំទ្រ
របស់ទាំងនោះ ដែលប្រទះឃើញនឹងព្រះនេត្រពុំបាន ព្រះហឫទ័យ
ស្រពោន ស្តេចចូលទៅរកក្រឹស្ណៈទាំងយប់ងងឹត ហើយត្រាស់ថា
«សង្គ្រាមដ៏ពន្លឹកមុខគួរឲ្យព្រឺរោមនេះ មិនបានជាផលប្រយោជន៍អ្វី
ទេ ការបំផ្លិចបំផ្លាញញាតិមិត្រឲ្យរលំរលាយគ្មានទីបំផុតនេះ ជាកម្ម
របស់ខ្ញុំ មិត្ររបស់យើងជាសត្រូវនឹងយើង ឯការដែលយើងកាប់
សម្លាប់គេនោះ គឺឈ្មោះថាយើងសម្លាប់ខ្លួនយើងហ្នឹងឯង បានស៊ូ
ទ្រាំច្បាំងកាប់សម្លាប់គ្នា ឈាមហូរដាបទាំងម្លេះ មើលទៅយើងក៏មិន
ឃើញជានឹងជិតទៅទីដំរូយនៃជ័យជម្នះនោះឡើយ ដឹងជាកាលណា
នឹងដល់នូវទីបំផុត ពួកកុរុក៏មិនរាថយត្រង់ណា គេនៅតែមានជ័យ
របូតមកគ្មានអ្នកណានឹងអាចទប់ទល់កម្លាំងភីស្មៈ អ្នកឈ្នះគ្រប់
ទិសនោះបាន ការនេះជាការនាំឲ្យរវល់តែនឿយព្រួយឥតអំពើ នាំឲ្យ
លំបាកទទេៗ បង់ជីវិតអសារឥតការ តស៊ូនឹងកម្មនិយមទទេ
ទាហានរបស់យើងមានឈាមហូរចេញទទេ, រាស្ត្ររបស់យើងលះ
បង់ជីវិតឲ្យយើងទទេ, ជាតិទាំងឡាយបានលះបង់ជីវិត និងលោហិត
របស់គេដើម្បីឃើញដល់យើង ជួយយើងក៏ទទេ នៃក្រឹស្ណៈអើយ ! ខ្ញុំ



ទ្រាំមិនបាន ហើយចូរឈប់កាប់សម្លាប់គ្នាដោយឥតរើសមុខទៅចុះ
ហើយយើងក៏នឹងនាំគ្នាទៅនៅក្នុងព្រៃម្តងទៀតចុះ» ។

កាលជាខាងក្រោយពីការប្រឹក្សានឹងក្រឹស្ណៈ យុធិស្ឋិរបានហៅ
ប្រជុំនៅវេលាអគ្រាត្រស្ងាត់ ដើម្បីនឹងចាត់ការរឿងនោះ ឲ្យបានសុខ
សាន្តត្រាណ លុះស្រេចការប្រជុំហើយ ទើបត្រាស់ប្រើឲ្យទាហានអ្នក
មុខអ្នកការខាងបាណ្ឌពជាច្រើននាក់ ឲ្យចូលទៅរកភីស្មៈ ទូលអង្វរ
សូមឲ្យមេត្តាករុណាក្នុងការដែលនឹងឈប់ស្លេះលើកលែងធ្វើ
សង្គ្រាមតទៅទៀត ។ លោកអ្នកចម្បាំងបុរាណបានធ្វើបដិសណ្ឋារ
ដោយសេចក្តីអើពើជាបំផុត ប៉ុន្តែត្រង់រឿងដែលសុំឲ្យមេត្តាករុណា
នោះ ភីស្មៈឆ្លើយតបវិញថា «បើគេមានជីវិតរស់នៅដរាបណា នឹង
ចេះតែស៊ូទ្រាំច្បាំងដណ្តើមយកជ័យឲ្យទុរយោធន៍ដរាបនោះ» ។

ភីស្មៈបានធ្វើសច្ចាប្រណិធានទុកក្នុងរឿងនេះ ជាយ៉ាងមាំមួន
ជាសំដីនៃអ្នកចម្បាំងដែលមានអាការៈប្រៀបដូចភ្លុកដំរី គេនឹងមិន
ព្រមលះបង់នូវពាក្យនេះចោលទេ ប៉ុន្តែគេកាន់ច្បាប់ដូចក្សត្រិយ៍អ្នក
ចម្បាំង គឺគេតាំងសច្ចាប្រណិធានថា នឹងមិនច្បាំងកាប់សម្លាប់សឹក
ដែលចាលចាញ់ហើយ ឬសឹកដែលគេចរត់មិនតដៃ ឬដាក់អាវុធ
ចេញស្រែកសុំសេចក្តីករុណា ឬសឹកដែលញ័របញ័មចុះចាញ់ ឬអស់
កម្លាំង ឬត្រូវអាវុធ ឬក៏មានភេទជាស្ត្រីភាព ។

ពួកមេទ័ពអម្បាលនោះ នាំគ្នាត្រឡប់ទៅបន្ទាយដោយសេចក្តី

រីករាយសមប្រាថ្នា ប្រាប់អរជុនថា «ឥឡូវនេះ មានផ្លូវសង្ឃឹមថាមុខជាមានជ័យហើយ ដ្បិតភីស្មៈបានតាំងសច្ចាប្រណិធានថា គេនឹងមិនច្បាំងជាមួយបុគ្គលជាភេទស្ត្រីភាព យើងមានមនុស្សដូចគេថានេះម្នាក់នៅក្នុងកងទាហានរបស់យើង, លោកយល់ដូចម្តេចសិខណ្ឌិន ? សិខណ្ឌិន កើតមកជាភេទស្ត្រី ប៉ុន្តែកាលពីក្មេងនៅឡើយបានប្តូរភេទនឹងយក្សម្នាក់ ខ្លួនគេក៏ក្លាយទៅជាភេទបុរសវិញ ដូច្នេះចូរឲ្យសិខណ្ឌិនទៅកងមុខនៃកងទ័ពយើង ភីស្មៈឃើញមុខជាដកទ័ពថយចេញចោលយើង ទុកឲ្យយើងនៅជាម្ចាស់ទីយុទ្ធ ដោយមិនបាច់សង្ស័យ»។

អរជុនកាលបានស្តាប់ពាក្យប្រឹក្សានេះចប់ហើយ ក៏ក្រេវក្រោធប្រឡោតឡើងហើយស្រែកយ៉ាងខ្លាំង ៗ ថា «អាម៉ាស់មុខណាស់លោកអើយ ! អ្នកចម្បាំងដ៏សុចរិតឯណា គេនឹងសុខចិត្តបន្ទាបខ្លួនទៅធ្វើលួចល្បក់ស្ទាត់កំបាំងយ៉ាងនេះ ឬនឹងលាក់សេចក្តីក្លាហានទុកក្រោយខ្នងស្ត្រី ឬកូនក្មេង, ខ្លួនយើងម្នាក់ហើយ មុខជាមិនព្រមច្បាំងដោយអាការកម្លាចយ៉ាងនេះទេ, មិនព្រមយកឧបាយកល ដ៏អាម៉ាស់មុខយ៉ាងនេះ ទៅរំលើងរំលាយភីស្មៈ អ្នកឥតមន្ទិលនោះទេ, វិធីកោងបែបនេះ ធ្វើឲ្យខូចកេរ្តិ៍ឈ្មោះ កិត្តិយសរបស់យើង» ។

ក្រឹស្ណៈក្រោកឈរឆ្លើយតបនឹងអរជុនថា«វាដល់កាលមិគសញ្ញីសំគាល់ថា ជាសត្វម្រឹគដោយព្រហ្មលិខិតហើយ ថាថ្ងៃស្អែកនេះ



ភីស្មៈនឹងដួល, កាលបើភីស្មៈបានច្បាំងនឹងអ្នកដែលគេស្រឡាញ់យ៉ាងណា, អរជុនអើយ ! ទ្រង់ក៏ត្រូវតែច្បាំងនឹងព្រះញាតិរបស់ខ្លួនយ៉ាងនេះដែរ គេបានសម្តែងឲ្យទ្រង់ឃើញហើយតើ ក្សត្រិយ៍អ្នកចម្បាំងត្រូវតែច្បាំងគ្រប់មុខសព្វទិស មិនថាសត្រូវដែលខ្លួនស្រឡាញ់ ឬសត្រូវដែលខ្លួនស្អប់ទេ ដែលមកហើយក៏ត្រូវតែលេចចេញសងទៅវិញជាដរាប ខ្ញុំសូមទូលទ្រង់ វាគ្មានបាបកម្មអ្វីទេ ត្រង់ការដែលឲ្យសិខណ្ឌិន នាំកងទាហានរបស់យើងនោះ វេលាដែលគេកើតមកហើយ ទោះបីគេកើតជាអ្វីក៏ដោយ ឥឡូវនេះគេជាអ្នកចម្បាំងម្នាក់ដូចទ្រង់ដែរ ត្រូវតែឲ្យគេធ្វើនាទីនោះបាន គ្មានឧបាយកលខូចកាចឃោបល់កោង ដូចដែលទ្រង់នឹកក្រែងនោះទេ» ។

កាលបានស្តាប់ពាក្យរំឭកសតិ ដូច្នោះហើយ អរជុនក៏ចេញច្បាំងក្នុងថ្ងៃទី ១០ មានសិខណ្ឌិនជាអ្នកនាំទ័ពនៃបាណ្ឌព ។ ទុរយោធន៍កាលបានឃើញមេទ័ពថ្មីនាំទ័ពយុធិស្ឋិរ ក៏ទទូចអង្វរភីស្មៈម្តងទៀតដើម្បីឲ្យលះបង់តំណែងជាមេទ័ព ប្រគល់ទៅឲ្យកណ៌វិញដោយហេតុទ្រង់យល់ឃើញថា ក្នុងរាជទាហានត្រូវតែផ្លាស់ប្តូរជាដរាប, ទ្រង់យល់តទៅទៀតថា មេទ័ពតែម្នាក់នាំទាហានចេញច្បាំងរាល់ ៗ ថ្ងៃ មិនផ្លាស់ប្តូរគ្នាខ្លះដូច្នេះ ជាការចង្អុលប្រាប់សេចក្តីខ្វះខាតមេទ័ព ដែលខ្លាំងពូកែក្នុងកងទ័ពកុរុ, ទ្រង់យល់ឃើញថា ការផ្លាស់មេទ័ពនោះ មិនមែនគ្រាន់តែធ្វើឲ្យសម្រើបចិត្តរបាំពលប៉ុណ្ណោះទេ

ថែមទាំងធ្វើឲ្យពួកសឹកសត្រូវញញើតថ្វីដៃនៃមេទ័ពថ្មីនោះផងទៀត, កាលទ្រង់បានឃើញពួកបាណ្ឌពរើសមេទ័ពជាថ្មី ទ្រង់ក៏ចង់ដំណើរការតាមគេដែរ ព្រោះទ្រង់យល់ឃើញថា ការដែលធ្វើដូច្នោះ ជាអាការៈសម្តែងឲ្យដឹងថា ទ្រង់នៅមានសេចក្តីស្មើមុខនឹងសឹក ទើបទ្រង់អង្វរភីស្មៈម្តងទៀត ឲ្យប្រគល់តំណែងមេទ័ពទៅកណ៌ ប៉ុន្តែភីស្មៈប្រកែកដាច់អហង្ការថា «ថ្ងៃនេះ ខ្ញុំនឹងកម្រាបពួកបាណ្ឌពក្សត្រិយ៍ឲ្យរាបទាល់តែបាន ឬបើមិនដូច្នោះទេ ខ្លួនឯងនឹងស្លាប់ក្នុងទីយុទ្ធភូមិប៉ុណ្ណោះ កុំបាច់រំខានព្រះទ័យថ្វីឡើយ, ការបានសម្រេចដូចសេចក្តីប្រាថ្នារបស់ព្រះអង្គនោះ នៅមិនឆ្ងាយប៉ុន្មានទេ» ។

ពោលប៉ុណ្ណោះហើយ វីរបុរសជរាក៏បររថស្ទៅចេញទៅ ត្រាស់ឡកឡឺយឲ្យអរជុន ។ អ្នកចម្បាំងទាំងពីរគ្រាណា ៗ មក មិនដែលមានដូចជាគ្រានេះទេ ។ ភីស្មៈ និងអរជុន មួយគូនេះជាអ្នកចម្បាំងឯករកបុគ្គលប្រៀបគ្មាន ។ គេតស៊ូគ្នាគ្រានេះ បានបញ្ចេញស្នៀតគ្រប់យ៉ាង មុខគួរឲ្យចង់មើលជាបំផុត ។ ពួកទាហានទាំងពីរខាងជាច្រើនអ្នកនាំគ្នាមកឈរជំកង់ជុំវិញទីនោះ ដើម្បីមើលការប្រយុទ្ធរវាងវីរបុសទាំងពីរប្រាណ ។

កាលការតស៊ូគ្នាដល់កម្រិតជាន់ខ្ពស់បំផុតហើយ ក្សិណនោះសិខណ្ឌិន ស្រាប់តែលេចផ្លោចូលមកព្រួតវាយភីស្មៈពីខាងក្រោយដោយមិនដឹងខ្លួន ។ លុះភីស្មៈក្រឡេកមើលឃើញ ក៏រឭកនឹកដល់



ពាក្យប្តេជ្ញាថា «នឹងមិនច្បាំងតស៊ូជាមួយអ្នកកើតមកជាភេទស្ត្រី» កាលរឭកដល់សំដីនោះហើយ ដៃរបស់គេសម្របចុះ ដងធ្នូក៏ធ្លាក់ចុះអំពីដៃដែរ ។ ភីស្មៈនៅវេលានោះ បើនឹងប្រៀបទៅវិស័យដូចដំបូក ។ ខណៈនោះ ស្រាប់តែកូនសររបស់អរជុន រត់ប្រសាចមកចាក់ដោតកាយភីស្មៈ មុតសុសសព្វអន្លើ ។ ទោះបីដល់ម្លេះក្តី វីរបុរសជរាសក់ស្កូវព្រាងពេញព្រះសិរក៏ឈរជង្រ្គឹង ឬកក្រអឺតនៅលើរថបីដូចជាបពិត លោហិតហូរស្រោចកាយជោក នៅតែមិនសម្តែងអាការៈទុរន់ទុរាសោះឡើយ លុះយូរបន្តិចទើបមានអាការៈឲ្យងងឹតមុខ ប៉ុន្តែទោះបីដល់ម្ល៉ឹងហើយ ក៏នៅតែឈរខ្ជាប់ខ្ជួននឹងកន្លែង ក្នុងទីបំផុតគេដឹងខ្លួនថាការប្រឹងប្រែងរបស់គេ ចាត់ជាការប្រឹងប្រែងមែនទែនហើយ, ការប្រឹងប្រែងដណ្តើមយកកេរ្តិ៍ឈ្មោះជាតិអ្នកចម្បាំងរបស់គេ ទុកឲ្យគង់ដល់ទីបំផុតប៉ុណ្ណោះហើយ ទើបគេដួលចុះកណ្តាលស្នាមយុទ្ធ ដួលដូចក្សត្រិយ៍ជាតិអ្នកចម្បាំង ។ ភីស្មៈតាំងពីចូលកាន់ស្នាមយុទ្ធមក តែងតស៊ូនឹងសឹកសត្រូវឥតល្ហែ រហូតដល់ទីបំផុតនេះឥតថ្ងូរ ឥតដកដង្ហើមធំទេ ទាំងមិនព្រមឲ្យអ្នកណាដកព្រួញធ្នូ ដែលដោតជាប់នឹងខ្លួននោះចេញផង ថ្នមទុកតាងពូកគ្រែរងរាងកាយ ក្នុងគ្រាដេក ។

ភីស្មៈ កំពូលពលផ្ទំទាំងព្រួញធ្នូស្អេកស្កះពេញខ្លួនយ៉ាងនេះក្នុងទីយុទ្ធភូមិ ព្រះសុរិយាក៏ទន់ទាបបិទបាំងបព្វតា ដូងតារារៀងរះ

ព្រោងព្រាយក្នុងអម្ពរ បញ្ចេញរស្មីត្រជាក់ស្រទន់ មកប៉ះព្រះភក្ត្រដ៏ស្រស់របស់លោកស្តេចសឹក ដែលដួលដេកនោះ ។

អ្នកចម្បាំងជរាផ្ទុំយ៉ាងសង្ហា ព្រមដោយយស និងបរិវារ ឥតយកចិត្តទៅចាប់នឹងសេចក្តីឈឺក្តៅរោលរាល ក្នុងកាយជាអារម្មណ៍សោះ បានសន្ទនារីករាយជាមួយអ្នកទាំងពួង ដែលទៅចោមរោមជុំជិតខ្លួន ដើម្បីសម្តែងសេចក្តីសោកស្រណោះ ។ អ្នកកាន់ទុក្ខទាំងពួងរួមទាំង អរជុន និងយុធិស្ឋិរផង ក៏រាប់បញ្ចូលក្នុងចំនួននោះដែរ ។ ទុរយោធន៍ ព្រមទាំងបងប្អូនរបស់ព្រះអង្គ បានស្តេចប្រញាប់មកកាន់ទីនោះសន្សឹម ៗ ចូលទៅគង់ក្បែរខាងអ្នកចម្បាំងដែលដួលនោះ ប៉ុន្តែនៅមិនទាន់ក្សយព្រះជន្ម ។

ភីស្មៈប្រាស្រ័យនឹងទុរយោធន៍ជាមុន ព្រោះព្រះហឫទ័យកង្វល់បលិពោធនឹកតែទុរយោធន៍មួយអង្គជាងគេ ទ្រង់ឲ្យឱវាទដល់ទុរយោធន៍ជាច្រើនយ៉ាង ដោយទ្រង់ព្រះតម្រិះថា បច្ឆិមវាចារបស់ទ្រង់ក្នុងគ្រាបំផុតនេះ ប្រហែលជានឹងធ្វើឲ្យចាប់ចិត្តចាប់ថ្លើម ដ៏របឹងរឹងរូសរបស់ទុរយោធន៍ជាងពីកាលដែលរួចមកហើយ ទើបថ្លែងសន្ទរកថាថា «ចូរស្តាប់ពាក្យរបស់ខ្ញុំ ក្នុងកាលឥឡូវនេះ ទុរយោធន៍អើយ ! ចូរស្តាប់ពាក្យបណ្តាំមុនស្លាប់របស់ញាតិភក្តី ថាបើទ្រង់នៅមានព្រះហឫទ័យសង្វេគវេទនាខ្លះដែរសោត ក៏ចូរឲ្យលើកលែងកាប់សម្លាប់ពពួកញាតិដោយដៃរបស់ខ្លួននេះចេញ, ក្សត្រិយរាជអើយ ! ចូរទុក



ជីវិតបណ្តាក្សត្រិយ៍អ្នកក្លាហានដែលជាប់តាមព្រះអង្គមកក្នុងរាជការកម្រាបសឹកសង្គ្រាមក្នុងយាមសុខ និងយាមទុក្ខ កុំឲ្យជាតិកុរុដ៏ក្លាហាននេះសាបសូន្យទៅឡើយ ចូរបង្វិលអាណាចក្រឥន្ទ្របថ ដ៏ជារបស់គេដោយយុត្តិធម៌នោះ ឲ្យដល់យុធិស្ឋិរ អ្នកទ្រង់សីលបរិសុទ្ធនឹងទ្រង់សត្យរកទីដំណៀលគ្មានទៅវិញទៅ, សូមឲ្យពួកកុរុ និងបណ្ឌុនៅជាសុខ និងភាតរភាពផងគ្នាមួយគ្រាទៀតចុះ នេះជាពាក្យសុំគ្រាទីបំផុតរបស់ខ្ញុំ» ។

ទុរយោធន៍មានសេចក្តីសង្វេគវេទនា អាណិតលោកស្តេចសឹកដែលជិតមរណៈនេះខ្លាំងណាស់ ប៉ុន្តែបច្ឆិមវាចារបស់លោកចោមពលនោះ ជាវាចាអសារឥតការក្នុងកមលហឫទ័យទុរយោធន៍ មិនទទួលអើផងទេ ព្រះហឫទ័យទ្រង់ បង្អោនទៅតែក្នុងការរំលាងពួកបាណ្ឌព ឲ្យរលាយរលីងអស់ទៅ ហើយនឹងកោងរឹបយកអាណាចក្ររបស់គេ ហេតុដូច្នោះ ទ្រង់ក៏តាំងព្រះហឫទ័យនឹងធ្វើសង្គ្រាមតទៅទៀត ចេះតែខំស៊ូច្បាំងទាល់តែនៅសល់ទាហានម្នាក់ តយុទ្ធនឹងអរិរាជសត្រូវទើបឈប់ ។

ខណៈនោះ កណ៌ចូលមករកវីរបុរសដែលជិតមរណៈ ។ កណ៌មិនចូលចិត្តនឹងភីស្មៈមកយូរហើយ ព្រោះនឹកឫស្យានឹងតម្រិះវិជ្ជាដ៏វិសេសរបស់ភីស្មៈ និងតំណែងយសស័ក្តិដ៏ខ្ពង់ខ្ពស់ដែលភីស្មៈទទួលកាន់កាប់ក្នុងវេលានេះ គឺធ្វើជាមេទ័ពធំបំផុតបង្គាប់បញ្ជាកងទ័ពកុរុ ។

នៅវេលាដែលលោកស្តេចសឹកជរា ផ្ចំចាំទទួលមច្ចុរាជហើយ កណ៌ជាគូសត្រូវចាស់ ក៏ភ្លេចរឿងប្រកួតអួតឫទ្ធិគ្នា បានចូលមកសម្តែងស្មាលាទោស និងមេត្តាចិត្ត សន្សឹម ៗ លប ៗ ចូលមកជិត ដើម្បីមិនឲ្យខ្វាំងខ្វប់ចិត្តលោកស្តេចសឹក ។ ភីស្មៈបានឮស្វរជើងដើរ ក៏ហៅឲ្យចូលមកជិតខ្លួន ហើយនិយាយយ៉ាងផ្អែមល្ហែម ទឹកព្រះវាចាពេញទៅដោយស្នេហាប្រណីថា «យើងធ្លាប់ជាអ្នកប្រកួតប្រណាំងគ្នា តាំងពីកាលណា ៗ មកហើយ មានចិត្តច្រណែនឫស្យាឈ្នានិះសតិបញ្ញានឹងកិត្តិយសកេរ្តិ៍ឈ្មោះរបស់គ្នានូវគ្នា នឹងប៉ុនប៉ងតែផ្ដិលផ្ដាច់ជីវិតគ្នាជានិច្ច, នៅវេលានេះសូមឲ្យអហោសិកម្ម ឈប់ឫស្យាព្យាបាទអាឃាតគ្នាទៅចុះណា យើងមានសេចក្ដីមួយរឿងដែលគួរនឹងបញ្ចេញឲ្យអ្នកស្ដាប់ ប៉ុន្តែក្រែងជីវិតរបស់យើងផុតទៅមុនផ្ដាំសេចក្ដីចប់ ទោះបីដូចម្ដេចក្ដី ក៏យើងសុំនិយាយដោយស្ងាត់កំបាំងរបស់អ្នក ដែលខ្ញុំខំបិទបាំងទុកមកយូរហើយ ៖ «អរជុននេះមិនមែនជាមនុស្សខ្លាំងពូកែជាងអ្នកដោយហេតុណាមួយទេ មិនមែនឈ្លាសវៃជាងអ្នកក្នុងវិជ្ជាចម្បាំងទេ ឬស័ក្តិយសត្រកូលក៏មិនខ្ពង់ខ្ពស់ជាងអ្នកដែរ ព្រោះអ្នកក៏ជាជាតិក្សត្រិយ៍ជាប់ខ្សែលោហិតជាមួយគ្នានឹងគេ អ្នកឯងជាឱរសព្រះនាងកុន្តី និងសូរ្យទេព, កាលព្រះនាងប្រសូតអ្នកមកក្នុងគ្រាព្រះនាងនៅជាក្រមុំនៅឡើយ សូរ្យទេពជាជនករបស់អ្នក, កាលអ្នកនៅជាកុមារ គេយកអ្នកទៅដាក់ចោលលើផែនថ្ម ដើម្បីឲ្យស្លាប់បង់ទៅ



នឹងបានចៀសវាងឲ្យផុតអំពីសេចក្ដីអាម៉ាស់មុខ នៃមាតារបស់អ្នក, គ្រានោះមាននាយសារថីម្នាក់បានទៅជួបប្រទះ ក៏រើសយកខ្លួនអ្នកទៅផ្ទះចិញ្ចឹមទុកជាបុត្ររបស់គេរហូតមក, ដូច្នេះ អរជុនក៏ជាបងប្អូនរបស់អ្នកឯង ឯសង្គ្រាមដែលយើងធ្វើវេលានេះ ជាសង្គ្រាមរវាងវង្សញាតិយើងហ្នឹងឯង នេះជាការមិនគួរគប្បីសោះ តអំពីនេះទៅទៀត ជាធុរៈរបស់អ្នកដែលនឹងត្រូវនាំសង្គ្រាម ទៅកាន់សេចក្ដីចប់ស្រេចអស់ដោយឆាប់ ៗ» ។

កណ៌ភ្ញាក់ខ្លួនព្រឹត ដោយបានឮភីស្មៈបង្ហើបប្រាប់អាថ៌ស្ងាត់កំបាំងនៃជាតិកំណើតរបស់ខ្លួន ប៉ុន្តែមានចិត្តក្រេកអរត្រង់ពាក្យដែលថាគេជាកូននាយសារថីត្រកូលថោកទាបនោះ មិនពិតប្រាកដទៅហើយ សម្លេងតិះដៀលអស់នេះ មុខជាលែងមានតទៅទៀត ប៉ុន្តែអាក់អន់ចិត្តត្រង់ពាក្យដែលថាត្រូវរាប់អានអរជុនជាបងប្អូន បណ្ដាមនុស្សក្នុងសកលលោកនេះ អរជុនជាអ្នកចម្បាំងដែលគេច្រណែនឫស្យាស្អប់បំផុត អរជុនជាសឹកសត្រូវនឹងគ្នា ដែលគេចង់តែគ្រញេចឲ្យខ្ទេចបាត់បង់ទៅតាំងពីនៅកុមារតូច បានចូលប្រឡងរះអាវុធគ្នា គេមានចិត្តច្រណែនឫស្យាអរជុនយ៉ាងខ្លាំង បានជាមានសេចក្ដីប៉ុនប៉ងកាច់គូសត្រូវនេះ ឲ្យរាបទាបទាល់តែបាន ព្រោះហេតុនេះពាក្យភីស្មៈដែលសុំឲ្យគេ «នាំសង្គ្រាមទៅកាន់សេចក្ដីឆាប់ស្រេចអស់ទៅ» នោះចូលទៅប៉ះពាល់ដល់ដួងហឫទ័យកណ៌តិចណាស់ ប្រហែល